ទស្សនាវដ្តី

ប្រជាជន

THE PRACHEACHUN MAGAZINE

ឆ្នាំទី២១ លេខ ២៤២ ខែកក្កដា ឆ្នាំ ២០២១

និពន្ធនាយក :

លោក តាក ស៊ុនអ៊ី

គណៈកម្មការនិពន្ធ

១. លោក ខ្សៀវ ណារី

២. លោក អ៊ឹម សុន្ទរៈ

៣. លោក វង្ស សាវុធ

៤. លោក ទាវ សារៈមុនី

៥. លោក សុខ សុធន

លេខានិពន្ធ

១. លោក ស្វាយ ភីរុណ

២. លោក ម៉ក់ ឈិន

អ្នកបកប្រែភាសា

១. លោកស្រី ម៉ែន នារីសោភ័ត

អ្នកថតរូប

១. លោក សុផាត វីរៈមុនី

វិចិត្រករ

១. លោក ធា សាវុធ

អាស័យដ្ឋាន :

លេខ ២០៣

មហាវិថី ព្រះនរោត្តម

ភ្នំពេញ-កម្ពុជា

ទូរស័ព្ទលេខ :

០២៣ ២១៩ ០៦៥

Address :

No 203 Preah

Norodom Bld.

Phnom Penh Cambodia

Tel : 023 219 065

សម្តេចតេជោ ហ៊ុន សែន ៖ ទោះជាតម្លៃណា ក៏ដោយជារាជការិយាល័យត្រូវតែសម្រេចឲ្យបាន នូវការចាក់វ៉ាក់សាំង.....

៥

សម្តេចតេជោ ហ៊ុន សែន ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា.....

៩

សម្តេចក្រឡាហោម ស ខេង ៖ បើមានបញ្ហាប៉ះពាល់ដល់ផលប្រយោជន៍ និងសិទ្ធិរបស់ប្រជាជនត្រូវធ្វើការដោះស្រាយ.....

១០

សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំបន្តសម័យប្រជុំលើកទី៧ ព្រឹទ្ធសភា .....

១១

ក្របមុខ

សម្តេចតេជោ ហ៊ុន សែន អញ្ជើញទទួលដោយផ្ទាល់នូវការមកដល់វ៉ាក់សាំងជំងឺកូវីដ-១៩ ដែលជាជំនួយរបស់រាជរដ្ឋាភិបាល និងប្រជាជនជប៉ុន

មាតិកា
Contents

វិចារណកថា : អនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់យុទ្ធសាស្ត្រទាំង ៦ ក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩..... ០១

Editorial : Highly Effective Implementation of the Six Strategies in Combating Covid-19 ..... ០១

- *អត្ថបទនយោបាយ: កលល្បិចទុច្ចរិតបំផ្លាញជាតិរបស់ពួកប្រឆាំងជ្រុលនិយម ០៤*
- *សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ១២*
- *សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ១៦*
- *សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច ១៨*
- *វិស័យព័ត៌មាន ដើរតួនាទីយ៉ាងសំខាន់ក្នុងការបម្រើផលប្រយោជន៍ជូនសាធារណជន..... ១៩*
- *វឌ្ឍនភាពនៃការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវជាតិ និងផ្លូវក្នុងក្រុង..... ២១*
- *លើកកម្ពស់សិទ្ធិ សេរីភាព សុខុមាលភាព និងគុណភាពជីវិតរបស់ជនមានពិការភាព..... ២៣*
- *អត្ថបទវប្បធម៌: ប្រវត្តិ ខេត្តព្រៃវែង..... ២៥*
- *ចំណេះដឹងទូទៅ: ថវិកាយោធាសកលកើនលឿនជាងថវិកាប្រឆាំងនឹងភាពអត់ឃ្លាន..... ២៦*
- *វិទ្យាសាស្ត្រ និងសុខភាព: គុណប្រយោជន៍ ១០យ៉ាងនៃការទទួលទានទឹកពេលព្រឹក..... ២៧*
- *កំណាព្យ: សំដីជាឯក លេខជាទោ អក្សរជាត្រី.....សំណើច..... ២៨*

វិចារណកថា EDITORIAL

អនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់យុទ្ធសាស្ត្រទាំង ៦ ក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩

Highly Effective Implementation of the Six Strategies in Combating Covid-19 Pandemic

នៅលើសមរភូមិប្រយុទ្ធប្រឆាំងជំងឺឆ្លងរាតត្បាតជំងឺកូវីដ- ១៩ ***សម្តេច-អគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្ត្រចំនួន៦ ដើម្បីឈានទៅបញ្ចប់នូវ* ***«ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ»*** *ឲ្យបានឆាប់រហ័ស នាពេលខាងមុខ។ យុទ្ធសាស្ត្រទាំង៦នោះរួមមាន៖* ***១-*** *ការទប់ស្កាត់ការនាំចូលនូវកូវីដបំលែងថ្មី (ដែលតា) ដែលជាមេរោគគ្រោះថ្នាក់បំផុត ដោយត្រូវអនុវត្តវិធានការ៥ រួមមាន៖ ពង្រឹងការគ្រប់គ្រងច្រកចេញចូលទាំងព្រំដែនគោក ទឹក និងផ្លូវអាកាស, ការធ្វើតេស្ត ពិសេសត្រូវធ្វើតេស្តរហ័សនៅតាមព្រំដែន, ធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ ពង្រឹង និងផ្គត់ផ្គង់មណ្ឌលចត្តាឡីស័ក ឱ្យបានគ្រប់គ្រាន់ ជាពិសេសខេត្តជាប់ព្រំដែនថៃ, ដាក់ព្យាបាលដាច់ដោយឡែកសម្រាប់អ្នកវិជ្ជមានមេរោគបំលែងថ្មី (ដែលតា) ហើយចត្តាឡីស័កត្រូវធ្វើដល់ ២១ថ្ងៃ* ***២-*** *ការកាត់បន្ថយតំបន់ឆ្លង និងចំនួនឆ្លងឱ្យមកនៅទាប ដោយប្រើវិធានការចំនួន៤ រួមមានវិធានការអប់រំវិធានការសុខាភិបាលវិធានការរដ្ឋបាល និងវិធានការច្បាប់* ***៣-*** *ការខិតខំរកវិធីព្យាបាលអ្នកជំងឺ ហើយកាត់បន្ថយអ្នកស្លាប់រហូតឈានទៅដល់គ្មានអ្នកស្លាប់។ដោយអនុវត្តនូវវិធានការចំនួន៥រួមមាន៖ ស្វះស្វែងរកប្រភពថ្នាំដែលមានប្រសិទ្ធភាព និងតាមពិនិត្យមើលការផ្តល់ថ្នាំ ដែលមានការផ្តល់ខុសគ្នានៅតាមទីតាំងព្យាបាល, រៀបចំមន្ទីរពេទ្យបន្ថែមនៅតាមស្រុក និងបំពាក់សម្ភារៈឱ្យបានគ្រប់គ្រាន់នៅតាមពេទ្យខេត្ត និងស្រុក ជាពិសេសម៉ាស៊ីន ICU, ហ្វឹកហ្វឺនគ្រូពេទ្យបន្ថែម ដើម្បីចូលបម្រើការងារប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩, ត្រូវបញ្ជាទិញសម្ភារៈឱ្យបានឆាប់ និងការដាក់ឱ្យព្យាបាលនៅតាមផ្ទះ* ***៤-*** *ការរុករក និងគ្រប់គ្រង ដែលយុទ្ធសាស្ត្រនេះ មានវិធានការ៥ រួមមាន៖ រៀបចំតំបន់យកសំណាក និងការយកសំណាកទៅពិនិត្យ, ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ និងខិតខំរកមេរោគបំលែងថ្មី, ពង្រីកការធ្វើតេស្តរហ័ស, រៀបចំការធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ រកឃើញហើយត្រូវទុកអ្នកជំងឺកន្លែងណា ព្យាបាលកន្លែងណា ឬឱ្យនៅព្យាបាលតាមផ្ទះ និងតាមដានដោយបច្ចេកវិទ្យាព័ត៌មាន* ***៥-*** *ការរៀបចំកប់ឬបូជាសពអ្នកជំងឺកូវីដ១៩ ឱ្យបានល្អតាមវិធានការ៤យ៉ាង៖ រៀបចំប៉ាឆានៅកន្លែងមិនទាន់មានប៉ាឆា, ប្រើប៉ាឆាតាមវត្តតែត្រូវធានាសុវត្ថិភាពដោយធ្វើការជាមួយព្រះចៅអធិការវត្ត, រៀបចំដីសម្រាប់កប់សពតាមប្រពៃណីរបស់ជនជាតិភាគតិច និងខ្មែរ-ឥស្លាម និង រៀបចំធលិតក្តាមឈូសឱ្យបានត្រឹមត្រូវសម្រាប់យកទៅបូជា ឬកប់ និង* ***៦-*** *យុទ្ធសាស្ត្រវ៉ាក់សាំងគឺត្រូវរកវ៉ាក់សាំងការពារជំងឺកូវីដ១៩ ឱ្យបានយ៉ាងហោចណាស់ចាក់ជូនប្រជាពលរដ្ឋឱ្យបាន១០លាននាក់នៅជំហានដំបូងនិងដល់ក្មេងអាយុក្រោម ១៨ឆ្នាំ។*

យើងគប្បីរំលឹកថា កម្ពុជា ធ្លាប់ទទួលរងនូវការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ គឺ ***«ព្រឹត្តិការណ៍ ៣ វិច្ឆិកា»*** *ដែលត្រូវបានបិទបញ្ចប់ទៅវិញនៅ*

In the battlefield against the Covid-19 epidemic, Samdech Akka Moha Sena Padei Techo Hun Sen, Prime Minister of the Kingdom of Cambodia, outlined six strategies towards putting a complete end to the "February-20 Community Outbreak Event" quickly in the short coming time. The six strategies include (1) preventing the import of new Covid-19 variant (Delta), which is the most dangerous virus, by implementing five measures. The five measures are to strengthen the control of land, sea and air border crossings; to conduct rapid tests quickly at the border; to ensure quarantines measures; to supply needed materials for quarantine centers, especially in the provinces bordering Thailand; and to provide separate treatment for those who are positive of the corona variant (Delta). Those infected with the Delta variant must be in quarantine for up to 21 days. (2) Reduce the area of infection and the number of infections to a lower rate by using four measures, including education measures, health measures, administrative measures and legal measures. (3) Make efforts to find ways to treat patients and reduce deaths to zero. This effort must implement five measures, including: finding effective sources of drugs and monitoring the delivery of different drugs at treatment sites, setting up additional hospitals in districts and equipping provincial and district hospitals with adequate facilities, especially ICUs. While training additional doctors to work in the fight against Covid-19, order for equipment must be made as soon as possible and rules and regulation must be ready for home treatment guidance. (4) Searching for and managing the infected, whereby in this strategy consists of five measures, including setting up sampling sites and tests, strengthening laboratory capacity and striving for new variants, expanding rapid testing, setting up accurate quarantines; and where to leave patients for treatment - at a hospital or at home, and monitoring people's movement by information technology. (5) Burial or cremation preparation of the body of Covid-19 patients must be carried out according to 4 following measures. 1) Set up crematorium at places where there are none, and should there be a need to use existing crematorium in Buddhist pagodas, approval from the from the abbot must be obtained and safety must be ensured. 2) Look for the ground for burying the body according to traditions of ethnic Khmer and the Khmer-Muslim minority and the proper preparation

ថ្ងៃទី ១៨ ខែវិច្ឆិកា និង**«ព្រឹត្តិការណ៍ថ្ងៃទី ២៨ វិច្ឆិកា»** ដែលជាការឆ្លងចូលក្នុងសហគមន៍ជាលើកដំបូងបំផុតនៅកម្ពុជា ។ ប៉ុន្តែនៅក្នុងព្រឹត្តិការណ៍ទាំងពីរនេះមិនមានអ្នកស្លាប់ទេហើយអ្នកឆ្លងជំងឺកូវីដ-១៩សរុបមានត្រឹមតែចំនួន ៣៣៥ នាក់ប៉ុណ្ណោះ ។ នៅពេលនោះរាជរដ្ឋាភិបាលបានដាក់ចេញផែនការយុទ្ធសាស្ត្រ ដោយផ្តោតទៅលើមុខព្រួញចំនួន ៤ គឺ៖ ការទប់ស្កាត់ការឆ្លង និងការការពារអាយុជីវិតប្រជាជន, ការរក្សាលំនឹងជីវភាពប្រជាជន, ការខិតខំជួយឲ្យអស់លទ្ធភាពដើម្បីឲ្យធុរកិច្ច និងអាជីវកម្មអាចរស់បាន និងការរក្សាឲ្យបាននូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។ រាជរដ្ឋាភិបាលបានបែងចែកសមរភូមិប្រយុទ្ធជា៣ មុខព្រួញ គឺការប្រយុទ្ធ នឹងការឆ្លងចូលពីខាងក្រៅ, ការប្រយុទ្ធទប់ស្កាត់មិនឲ្យឆ្លងពីអ្នកមានជំងឺទៅអ្នកមិនទាន់មានជំងឺ និងការបន្តព្យាបាលអ្នកឆ្លងឲ្យបានជាសះស្បើយ។ នៅពេលនោះប្រជាជនកម្ពុជាបានចូលរួមយ៉ាងសកម្មដោយឈរលើស្មារតីនៃការប្រែក្លាយវិបត្តិនៃជំងឺនេះទៅជាកាលានុវត្តភាព ក្នុងការថែទាំសុខភាព ដោយចាប់ផ្តើមពីមនុស្សម្នាក់ៗ គ្រួសារនីមួយៗ រហូតដល់កម្រិតទូទាំងប្រទេស ។

បទពិសោធន៍ដ៏ល្អនេះ ក៏កំពុងត្រូវបានយកមកអនុវត្តបន្តទៀតនាពេលបច្ចុប្បន្ន ដើម្បីធ្វើឲ្យបានជោគជ័យនូវយុទ្ធសាស្ត្រទាំង ៦ របស់**សម្តេចតេជោ ហ៊ុន សែន** ។ យើងទទួលស្គាល់ថា វីរុសបំលែងខ្លួនកូវីដ-១៩ មានលក្ខណៈកាចសាហាវជាង និងបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរជាងកាលពីដំបូង ។ ជាក់ស្តែងនាពេលនេះ ជំងឺឆ្លងនេះ បានធ្វើឲ្យប្រជាជនកម្ពុជារាប់ម៉ឺននាក់ទទួលការឆ្លង ហើយចំនួនអ្នកស្លាប់ក៏មានច្រើន ដែលនោះ គឺជាសោកនាដកម្មមួយដ៏គួរឲ្យសោកស្តាយបំផុត ។ ប៉ុន្តែអ្វីដែលជាក្តីសង្ឃឹមរបស់យើងគឺកម្ពុជាមានវ៉ាក់សាំងគ្រប់គ្រាន់សម្រាប់ចាក់ការពារជូនប្រជាជន ដែលឆ្លុះបញ្ចាំងឲ្យឃើញពីភាពឈ្លាសវៃរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាដែលមានចក្ខុវិស័យវែងឆ្ងាយ ទូលំទូលាយ ច្បាស់លាស់ ក្នុងការដោះស្រាយបញ្ហាដោយចាត់ទុកអាយុជីវិតប្រជាជនជាធំ ហើយក៏បញ្ជាក់ថា កម្ពុជាជាប្រទេសក្រមែន ប៉ុន្តែមិនក្រគំនិតទេ ។ ការចូលរួមរបស់ ប្រជាជនក្នុងការទទួលវ៉ាក់សាំងក៏ដូចជា ការស្ម័គ្រចិត្តអនុវត្តនូវរាល់វិធានការសុខាភិបាលក៏ជាកត្តាកំណត់មួយដ៏សំខាន់ ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នេះដែរ ។ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រវ៉ាក់សាំងកូវីដ-១៩ ដោយរួមបញ្ចូលនូវផែនការជាតិចាក់វ៉ាក់សាំង និងគោលការណ៍ណែនាំប្រតិបត្តិសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងនេះ ដោយចាប់ផ្តើមដំណើរការជាផ្លូវការនូវការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ នៅថ្ងៃទី ១០ខែកុម្ភៈ ឆ្នាំ ២០២១ ។ មកដល់ដំណាច់ខែកក្កដានេះ យើងសម្រេចការចាក់វ៉ាក់សាំងជូនប្រជាជនបានលើសពី៥០% លើគោលដៅប្រជាជន ដែលត្រូវចាក់ចំនួន ១០លាននាក់ក្នុងទូទាំងប្រទេស ។រាជរដ្ឋាភិបាលបានគ្រោងចំណាយថវិកាចំនួន ១៧០ លានដុល្លារដើម្បីទិញវ៉ាក់សាំងឲ្យបានគ្រប់ ២០លានដូសគិតត្រឹមខែសីហា និងឈានទៅសម្រេចការចាក់វ៉ាក់សាំងបញ្ចប់ទាំងស្រុងនៅត្រឹមខែវិច្ឆិកា ឆ្នាំ២០២១ នេះ ។ និយាយរួម រាជរដ្ឋាភិបាល បានត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងម្ចាស់ការជាមុនក្នុងការដោះស្រាយបញ្ហាទាំងបញ្ហាពេលវេលា ទាំងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ធ្វើឲ្យយុទ្ធនាការជាតិចាក់វ៉ាកសាំងទទួលបានជោគជ័យដ៏ធំធេង ។ រាជរដ្ឋាភិបាលក៏បានធ្វើការដោះស្រាយ ការលំបាកក្នុងជីវភាពរស់នៅរបស់ប្រជាជន និងការធានាឲ្យមានស្ថិរភាពខាងសេដ្ឋកិច្ចសង្គមតាមរយៈការដាក់ចេញនូវវិធានការនានាសំដៅគ្រប់គ្រងផលប៉ះពាល់សេដ្ឋកិច្ចនៅក្នុងបរិការណ៍នៃវិបត្តិ, ការស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងអំឡុងនិងក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩

of coffins for cremation or burial. (6) Vaccination strategy is to find vaccines against Covid-19 to inoculate at least 10 million people in the first phase and to children under 18 years of age.

We should recall that Cambodia has suffered from the outbreak of Covid-19, the "November 3 event" which ended on November 18, and the "November 28 event" which was first community outbreak in Cambodia. However, no deaths were recorded in either of the two cases, and the total number of Covid-19 infected people were only 335. At that time, the Royal Government set out a strategic plan focusing on four areas: prevention of infection and protection of people's lives, maintaining the balance of people's lives, making efforts to help as much as possible for business and trades survival, and maintaining security and public order. The Royal Government has divided the battlefield into three main areas: the fight against external infiltration, the fight to prevent the spread of disease from the sick to the not sick ones, and continuing to treat infected people. At that time, the Cambodian people were actively involved in the spirit of turning the crisis of the disease into an opportunity for health care, starting from the individual to the whole family and to the national level.

This good experience is also being applied today to successfully achieve the six strategies of Samdech Techo Hun Sen. We recognize that the Covid-19 mutation virus is more virulent and more dangerous than it once was. In fact, the disease has now infected tens of thousands of Cambodians and the death toll is high, which is one of the saddest tragedies. What is our hope, however, is that Cambodia has enough vaccines to vaccinate its people, reflecting the wisdom of the head of the Royal Government of Cambodia, who has a clear, far-reaching vision in solving problems by considering the lives of the people as a whole. This confirms that though Cambodia is a poor country, it is not poor in thoughts. Public participation in vaccination as well as voluntary implementation of all health measures is also an important determinant factor in preventing the spread of Covid-19 disease. The Royal Government has launched the anti-Covid-19 vaccine strategy, including the National Vaccination Plan and the Operational Guidelines for the Vaccination Campaign, by officially launching the anti-Covid-19 vaccine on February 10, 2021.

By the end of July, we will have vaccinated more than 50% of the target 10 million population throughout the country. The Royal Government plans to spend US$ 170 million to purchase 20 million doses of the vaccine by August and to complete the vaccination by November 2021. In general, the Royal Government is ready and take ownership in advance to solve the problem of time, institutional capacity and human resources to make the national vaccination campaign a great success. The Royal Government has also addressed the people's livelihood

ដើម្បីកាត់បន្ថយផលប៉ះពាល់មកលើស្ថានភាពសេដ្ឋកិច្ចសង្គម និងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ក្នុងលក្ខណៈទ្រង់ទ្រាយធំ, ទ្រទ្រង់ និងស្តារអាជីវកម្ម និងធុរកិច្ចឲ្យដើរបង្កើងវិញដើម្បីជំរុញកំណើនសេដ្ឋកិច្ច សំដៅបង្កើតឲ្យបានភាពស៊ាំ សង្គមសេដ្ឋកិច្ចនៅក្នុងបរិការណ៍នៃការវិវឌ្ឍនៃជំងឺកូវីដ-១៩ និងការបន្តជួយទំនុកបម្រុងជីវភាពប្រចាំថ្ងៃរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ តាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ។ គិតត្រឹមថ្ងៃទី ២៥ ខែមិថុនា រាជរដ្ឋាភិបាល បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ បាន ៨ ជុំហើយ ដោយចំណាយថវិកាអស់ ៣៥០លានដុល្លារ ជូនទៅដល់ប្រជាជនជាង៦០ ម៉ឺនគ្រួសារ ។ រាជរដ្ឋាភិបាលបាននឹងកំពុងអនុវត្តកម្មវិធីនេះ សម្រាប់ ជុំទី ៩ ជាបន្តទៀត ។ បទពិសោធន៍ សំខាន់មួយទៀតគឺ ស្មារតីសាមគ្គីជាតិ និងការជួយទំនុកបម្រុងឧបត្ថម្ភគ្នាក្នុងចំណោមប្រជាជនកម្ពុជា គួរឲ្យកោតសរសើរយ៉ាងក្រៃលែងនោះគឺ ការផ្តល់ថវិកាពីសំណាក់សប្បុរសជននានា ដើម្បីជួយសម្រាលបន្ទុករាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ តាំងពីដំណាក់កាលដំបូងរហូតមកដល់បច្ចុប្បន្ន សរុបមានចំនួនជាង១៣០ លានដុល្លារហើយ ។ ទង្វើនេះបានឆ្លុះបញ្ចាំងឲ្យឃើញពីទឹកចិត្តរបស់ប្រជាជនកម្ពុជា ទូទាំងប្រទេស ដែលបង្កើតបានជាចលនាជាតិក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។

ប៉ុន្តែនៅក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩នេះ យើងនៅមានកត្តាហានិភ័យមួយចំនួនដែលត្រូវយកចិត្តទុកដាក់នោះគឺមេរោគបំលែងថ្មីដែលមានការឆ្លងខ្លាំង ហើយឆ្លងលឿន, ប្រជាជនយើងមួយចំនួន បានឆ្លងជំងឺនេះហើយ តែមិនមានចេញរោគសញ្ញា និងបន្តចំលងទៅអ្នកផ្សេងដោយលក្ខណៈស្ងាត់ស្ងៀម, ប្រជាជនខ្លះ មានភាពធូរលុង ក្នុងការអនុវត្តវិធានការសុខាភិបាល ។ យើងត្រូវទទួលស្គាល់ថា ស្ថានភាពជំងឺកូវីដ-១៩ នៅប្រទេសយើងសព្វថ្ងៃនៅតែមានលក្ខណៈធ្ងន់ធ្ងរជាស្ថានភាពអាសន្នមួយដែលតម្រូវឲ្យយើងទាំងអស់គ្នា ត្រូវបង្កើនល្បឿននៃកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ឈប់ការឆ្លងរាលដាលនេះ ។ យើងពិតជាមានការរន្ធត់ចិត្តខ្លាំងណាស់ចំពោះរបាយការណ៍ពីករណីស្លាប់ដំបូង ដោយសារជំងឺកូវីដ-១៩ កាលពីថ្ងៃទី ១១ ខែមីនា ឆ្នាំ២០២១ ហើយដែលមកដល់ពេលនេះ ចំនួនអ្នកស្លាប់បានកើនឡើងរាប់រយនាក់ ដែលសោកនាដកម្មនេះ ជាសារក្រើនរំលឹកប្រជាជនយើងទាំងអស់គ្នា អំពីភាពធ្ងន់ធ្ងរនៃជំងឺនេះ ហើយត្រូវតែបង្កើនការប្រុងប្រយ័ត្នខ្ពស់បំផុតព្រោះវាអាចវាយប្រហារយើងគ្រប់គ្នាក្នុងគ្រប់ពេលវេលាទាំងអស់។

ដោយបានធ្វើដំណើរឆ្លងកាត់នៅលើសមរភូមិប្រយុទ្ធប្រឆាំងនឹង ជំងឺកូវីដ-១៩ ជិត ២ឆ្នាំកន្លងមកនេះ យើងទទួលបាននូវបទពិសោធន៍ជាច្រើនទាំងចំណុចខ្លាំងដែលត្រូវបង្កើនការយកចិត្តទុកដាក់ ដើម្បីអនុវត្តបន្ត និងចំណុចខ្វះខាតដែលត្រូវធ្វើការកែសម្រួលឡើងវិញ ។ជាមួយនឹងបទពិសោធន៍ទាំងនេះ ប្រជាជនយើងទាំងអស់គ្នា សូមចូលរួមអនុវត្តឲ្យបានជោគជ័យនូវយុទ្ធសាស្ត្រទាំង ៦ របស់**សម្តេចតេជោ ហ៊ុន សែន** ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ក្នុងពេលដ៏ខ្លីខាងមុខនេះ ៕

ទស្សនាវដ្តីប្រជាជន

difficulties and ensured socio-economic stability by introducing measures aimed at managing the economic impact in the context of the crisis. It also aimed to rehabilitate and promote Cambodia's economic growth during and after the Covid-19 crisis to reduce the impact on the socio-economic situation and the risk of Covid-19 spread into the community on a large scale. Those measures also support and rehabilitate trades and businesses to promote economic growth aims to build socio-economic immunity in the context of the development of Covid-19 disease and to continue to support the daily lives of poor and vulnerable families through cash subsidies.

As of June 25, the Royal Government has implemented eight rounds of cash support programs for poor and vulnerable families during the fight against Covid-19, with a budget of US$ 350 million to reach more than 600,000 families. The Royal Government has been in the process of implementing this program for the ninth round. Another important experience is the spirit of national unity and mutual support among the Cambodian people, which is highly commendable, with donations from philanthropists with a totals amount of more than US$ 130 million, from the initial to the current phase, to help ease the burden on the Royal Government in the fight against Covid-19. This act reflects the morale of the Cambodian people throughout the country, which formed the national movement to fight Covid-19.

In the campaign against Covid-19, however, we still have a number of risk factors to take into account i.e. a new virus variant that is highly contagious and fast spreading. Some of our people have already had infection, but have not had symptoms, will continue to pass on to others quietly. Some people been less strict in taking health measures. We must recognize that the situation of Covid-19 in our country today is still serious, an emergency that requires all of us to step up our efforts to stop this epidemic. We are deeply saddened by the first reported death of Covid-19 on March 11, 2021, and the number of deaths so far has risen by hundreds, warning us of the severity of this disease and we must be extremely careful because it can strike us all at any time.

Having traveled through the battle of Covid-19 for the past two years, we have gained a wealth of experience, both strengths that we must work harder to expand and weaknesses that we needed to address. With these experiences, all of our people would like to join in successfully implementing the six strategies of Samdech Techo Hun Sen in the fight against Covid-19 in the near future./.

THE PRACHEACHUN MAGAZINE

សម្តេចតេជោ ហ៊ុន សែន ៖ ត្រូវបន្តអនុវត្តវិធានការសុខាភិបាល ដើម្បីរួមគ្នាទប់ស្កាត់ជំងឺកូវីដ១៩ និងស្រោចស្រង់សង្គមកម្ពុជាឡើងវិញនាពេលខាងមុខ

កលល្បិចខុសច្បាប់តែបំផ្លាញជាតិរបស់ពួកប្រឆាំងប្រជុលនិយម

ក្នុងពេលដែលប្រជាជនកម្ពុជា កំពុងតែខិតខំរកពេលស្ងើរតែដកដង្ហើមមិនបានក្នុងការប្រយុទ្ធប្រឆាំងជាមួយជំងឺកូវីដ-១៩ បែរជាមេឧទ្ធាមក្បត់ជាតិសម រង្សីប្រកាសពីក្រៅប្រទេសមក ដោយអំពាវនាវឲ្យមានការបង្កើតរដ្ឋាភិបាលបង្រួបបង្រួមជាតិមួយ។ រដ្ឋាភិបាលបង្រួបបង្រួមស្អីទៅ? តើនៅកម្ពុជាសព្វថ្ងៃនេះមានការបាក់បែកជាតិ មានសង្គ្រាម មានចលាចលនៅទីណា ដែលចាំបាច់ត្រូវតែបង្កើតរដ្ឋាភិបាលបង្រួបបង្រួមជាតិ? កោតតែសម រង្សីចេះនឹកឃើញទៅរួច.. ប៉ុន្តែរឿងស្អីក៏ដោយដែលអ្នកដទៃ ឬមនុស្សដែលមានសម្បជញ្ញៈគ្រប់គ្រាន់ មិនហ៊ានធ្វើដោយសារតែការខ្មាស់អៀននោះ គឺសម រង្សីអាចយកមកវ៉ាប់រងទទួលធ្វើបានទាំងអស់។ យើងពិតជានៅចងចាំទាំងហួសចិត្តថា ដោយសារតែមហិច្ឆតាអំណាចវាក្រាស់ឃ្មឹកខ្លាំងពេក សម រង្សី ក៏ធ្លាប់បានតែងតាំងខ្លួនឯងជានាយករដ្ឋមន្ត្រីស្រមោលជានាយករដ្ឋមន្ត្រីឧទាហរណ៍ថែមទៀតផង ។

ប៉ុន្តែភាពស្រមើស្រមៃរបស់ សម រង្សី លើកនេះមិនមែនថាអត់មូលហេតុនោះទេ។ ក្រោយពីត្រូវកប់បាត់ក្នុងធុងសម្រាមនយោបាយអស់មួយរយៈកាលធំបន្ទាប់ពីបរាជ័យក្នុងយុទ្ធនាការប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលក្នុងព្រឹត្តិការណ៍ខែវិច្ឆិកា ឆ្នាំ២០១៩ មកដល់ថ្ងៃនេះបុគ្គលនេះនៅតែមើលឃើញខ្លួនឯងថា កំពុងតែស្ថិតក្នុងធុងសម្រាមនយោបាយនេះដដែលទេ។ ដូច្នេះរូបគេត្រូវតែសាកល្បងមើលថា តើសន្ទុះនយោបាយរបស់ខ្លួននៅមានកម្រិតណា?មានអ្នកគាំទ្រខ្លួននៅខាងក្នុងប៉ុន្មាន ហើយនៅខាងក្រៅមានអ្នកគាំទ្រទៀតឬទេ រាប់ទាំងថៅហ្វាយរបស់គេផង? ប៉ុន្តែការសាកល្បងមួយទឹកចុងក្រោយនេះបានត្រឹមតែរុញច្រាន សម រង្សី ឲ្យធ្លាក់កាន់តែជ្រៅទៅក្នុងធុងសម្រាមនោះតែប៉ុណ្ណោះ។ ប្រជាជនក្នុងប្រទេសរាប់ទាំងអ្នកដែលធ្លាប់គាំទ្រ សម រង្សី ផងបានថ្កោលទោស សម រង្សី យ៉ាងធ្ងន់ធ្ងរ នេះយើងមិនទាន់រាប់អ្នកនយោបាយដែលធ្លាប់ចងសម្ព័ន្ធភាពនិងអ្នកវិភាគសង្គមដែលលំអៀងទៅរកជនឧទ្ធាមនេះដែលបានធ្វើការវាយប្រហារយ៉ាងចាស់ដៃ ដោយសារគេបារម្ភថាការអំពាវនាវទាំងស្រមើស្រមៃនេះ គ្រាន់តែបានជួយជំរុញប្រជាជនខ្លះដែលមិនយល់ឲ្យធ្លាក់ទៅក្នុងស្ថានភាព នៃការប្រព្រឹត្តអំពើល្មើសច្បាប់តែប៉ុណ្ណោះ។ ដោយឡែកបងប្អូនខ្មែរ យើងរស់នៅក្រៅប្រទេសសឹងតែមិនបានចាប់អារម្មណ៍បន្តិចណាទាល់តែសោះជាមួយនឹងការអំពាវនាវនេះដោយសារតែវាជាឆាកកំប្លែងដដែល សំដែងដោយតួសម រង្សីដដែល គឺវាគ្រាន់តែជារឿងដដែលៗរបស់សម រង្សី ។ ចំណែកមជ្ឈដ្ឋានបរទេសគឺមិនចាប់អារម្មណ៍សោះតែម្តងហើយពួកគេក៏ទំនងជាមិនយល់ថា សម រង្សី កំពុងលេងល្បែងអីផង ។ជាការពិតគ្មានរដ្ឋាភិបាលបរទេសណាមួយបញ្ចេញប្រតិកម្មពីរឿងនេះឡើយប្រហែលជាគេគិតថាមកដល់ពេលនេះហើយ ទុកឲ្យ សម រង្សី ប្រកាច់-ប្រកិនតែម្នាក់ឯងទៅចុះ។

នៅក្នុងជីវិតនយោបាយរបស់ខ្លួនមេឧទ្ធាមក្បត់ជាតិរូបនេះ ធ្លាប់បានកសាងកំហុសរាប់មិនអស់ចំពោះជាតិនិងប្រជាជន។ ជននេះធ្លាប់បានអំពាវនាវឲ្យកងទ័ព និងប្រជាជនក្រោកឈរឡើងធ្វើការផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ដែលកើតចេញពីការបោះឆ្នោត, ធ្លាប់បានធ្វើការជេរប្រមាថមកលើស្តាប័នព្រះមហាក្សត្រជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជាជន, ធ្លាប់បានវាយប្រហារដោយសំដីអសុរសទៅលើស្តាប័ននិតិបញ្ញត្តិ និងនីតិប្រតិបត្តិព្រមទាំងស្តាប័នដទៃទៀត រួមទាំងការវាយតម្លៃយ៉ាងទាបបំផុតទៅលើការយល់ដឹងរបស់ប្រជាជនកម្ពុជា ដោយការប្រើប្រាស់សំដីភូតកុហកនិងបោកប្រាស់សព្វបែបសព្វយ៉ាង។រាល់ទង្វើរបស់បុគ្គលសម រង្សីបានទទួលរងនូវពាក្យបណ្តឹងដែលមានរាប់សិបសំណុំរឿង ហើយដែលរឿងខ្លះក៏ត្រូវបានតុលាការកាត់សេចក្តីរួចស្រេចនិងសំណុំរឿងមួយចំនួនទៀតកំពុងតែដំណើរការនៅឡើយ។ គ្រាន់តែក្នុងមួយរយៈខ្លីចុង-ក្រោយនេះរឿងក្តីក្តាំរបស់សម រង្សីដែលយើងបានធ្វើការកត់សម្គាល់រួមមាន៖ ក្នុងអំឡុងខែធ្នូ ឆ្នាំ២០២០ សាលាដំបូងរាជធានីភ្នំពេញបានផ្តន្ទាទោស សម រង្សី ឲ្យជាប់ពន្ធនាគារ ៨ឆ្នាំពីបទបង្ករការញុះញង់ឲ្យមានភាពវឹកវរដល់សង្គម និងការញុះញង់ប្រជាជនកុំឲ្យសងបំណុលទៅធនាគារ។ នៅថ្ងៃទី២៨ ខែធ្នូ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញបានសម្រេចចោទប្រកាន់ សម រង្សី ពីបទប្រមាថ ព្រះមហាក្សត្រ ដែលទង្វើនេះជា ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ សាលាដំបូង រាជធានីភ្នំពេញបានប្រកាសសាលក្រមផ្តន្ទាទោស សម រង្សី ឲ្យជាប់ពន្ធនាគារ ២៥ឆ្នាំរួមទាំងបក្សពួកមួយចំនួនទៀតពីបទឧបឃាតពាក់ពន្ធ័ការធ្វើរដ្ឋប្រហារ ផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ក្រោមឧបាយកលជាផែនការនៃការវិលត្រឡប់ចូលប្រទេសកម្ពុជាអំឡុងព្រឹត្តិការណ៍ ៩វិច្ឆិកា ២០១៩។

នៅពេលនេះ ជីវិតនយោបាយរបស់ សម រង្សី មិនត្រឹមតែបានឈានមកដល់ទីបញ្ចប់ទាំងស្រុងនោះទេ ប៉ុន្តែបុគ្គលនេះនៅមានសំណុំរឿងជាច្រើនទៀតនៅក្នុងដៃតុលាការរាប់ទាំងតុលាការនៅក្រៅប្រទេសទៀតផងដែលគេត្រូវប្រឈមមុខដោះស្រាយ។ប្រជាជនកម្ពុជាគ្មានពេលវេលាដែលនឹងត្រូវចំណាយសម្រាប់គិតគូរពីបញ្ហានេះទេ។ បច្ចុប្បន្ននេះយើងទាំងអស់ កំពុងតែពួតដៃគ្នា រួបរួមគ្នាជាឆ្អឹងមួយ ប្រើប្រាស់ឲ្យអស់គ្រប់លទ្ធភាពនិងគ្រប់ពេលវេលាដែលមាន ដើម្បីគាំទ្ររាជរដ្ឋាភិបាលយើង ក្នុងការប្រយុទ្ធប្រឆាំងនៅលើសមរភូមិនៃជំងឺកូវីដ-១៩ ឲ្យទទួលបានជោគជ័យក្នុងពេលដ៏ឆាប់ខាងមុខ។ ព្រមជាមួយគ្នានេះប្រជាជនយើង បន្តការពង្រឹងជំនឿទុកចិត្តលើការដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងការថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ ស្ថិរភាពសង្គមសណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចដើម្បីកសាងសេដ្ឋកិច្ច-សង្គមកម្ពុជាឲ្យកាន់តែមានការរីកចម្រើនទៅមុខទៀតជានិរន្តរ៍៕

សម្តេចតេជោ ហ៊ុន សែន ៖ ទោះជាតម្លៃណាក៏ដោយរាជរដ្ឋាភិបាលត្រូវតែសម្រេចឲ្យបាននូវការចាក់វ៉ាក់សាំងជូនប្រជាជនកម្ពុជាដែលដល់អាយុត្រូវចាក់

❋ សម្តេចតេជោ ហ៊ុន សែន ៖ កម្ពុជាយកចិនជាបង្អែកយុទ្ធសាស្ត្រផ្គត់ផ្គង់វ៉ាក់សាំង ឯផ្សេងទៀតជាប្រភពគាំទ្រ

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញដឹកនាំកិច្ចប្រជុំពិសេសតាមប្រព័ន្ធវីដេអូ

❋ នៅព្រឹកថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញដឹកនាំកិច្ចប្រជុំពិសេសមួយតាមប្រព័ន្ធវីដេអូ ជាមួយគណៈកម្មការជាតិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដើម្បីពិភាក្សា និងដោះស្រាយទៅលើបញ្ហាជំងឺកូវីដ១៩។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា រយៈពេល ១៨ខែកន្លងទៅនេះ កម្ពុជាបានរួមគ្នាប្រយុទ្ធប្រឆាំង និងគ្រប់គ្រងស្ថានភាពជំងឺកូវីដ១៩ បានយ៉ាងល្អ។ យើងបានឆ្លងកាត់នូវព្រឹត្តិការណ៍មួយចំនួនដែលអាចគ្រប់គ្រងបានជាបន្តបន្ទាប់។ ពេលនេះយើងត្រូវអនុវត្តបន្តទៀតព្រោះអាចនឹងមានការឆ្លងរលកទី៣បើមិនមានចំណាត់ការទាន់ពេលវេលាទេ ពីព្រោះ ពេលនេះមានការរាតត្បាតថ្មីបង្កដោយមេរោគបំប្លែងខ្លួន **«ដែលតា»** ហើយមិនមែនតែករណីកម្ពុជានោះទេ គឺជាករណីព្រួយបារម្ភលើពិភពលោក ។

ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩នេះដែរ **សម្តេចតេជោ ហ៊ុន សែន** បានប្រកាសដាក់ចេញនូវយុទ្ធសាស្ត្រចំនួន ៦ចំណុច ដើម្បីបង្ការ ទប់ស្កាត់ និងដោះស្រាយបញ្ហាកូវីដ-១៩ នៅក្នុងប្រទេសឱ្យកាន់តែមានប្រសិទ្ធភាព ដែលរួមមាន៖ **យុទ្ធសាស្ត្រទី១-** ការទប់ស្កាត់ការនាំចូលនូវកូវីដបំប្លែងថ្មី (ដែលតា) កើតចេញពីឥណ្ឌា ដែលជាមេរោគគ្រោះថ្នាក់បំផុត ដែលត្រូវអនុវត្តវិធានការ៥ រួមមាន៖ ពង្រឹងការគ្រប់គ្រងច្រកចេញចូលទាំងព្រំដែនគោក ទឹក និងផ្លូវអាកាស, ការធ្វើតេស្ត ពិសេសត្រូវធ្វើតេស្តរហ័សនៅតាមព្រំដែន, ធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ ពង្រឹង និងផ្គត់ផ្គង់មណ្ឌលចត្តាឡីស័ក ឱ្យបានគ្រប់គ្រាន់ ជាពិសេសខេត្តជាប់ព្រំដែនថៃ, ដាក់ព្យាបាលដាច់ដោយឡែកសម្រាប់អ្នកវិជ្ជមាន មេរោគបំប្លែងថ្មី (ដែលតា) ហើយចត្តាឡីស័កត្រូវធ្វើដល់ ២១ថ្ងៃ ។ចំណែកពលករនៅ ប្រទេសថៃ មិនត្រូវបារម្ភទេកម្ពុជា បានសហការជាមួយថៃរួចហើយ ។ ភាគីថៃ បានបញ្ជាក់ហើយសម្រាប់អ្នកធ្វើការខុសច្បាប់នៅថៃ ក្នុងកំឡុងពេលកូវីដ-១៩ នេះ មិនមានការដាក់ទោសទណ្ឌទេ ហើយនឹងជួយផ្តល់ភាពស្របច្បាប់ថែមទៀតផង ។ សម្តេចតេជោអំពាវនាវដល់ពលករត្រូវនឹងនរចិត្ត កុំសម្រុកចេញពីថៃមកកម្ពុជា ដែលប្រឈមការឆ្លងជំងឺ, **យុទ្ធសាស្ត្រទី២-** ការកាត់បន្ថយតំបន់ឆ្លង និងចំនួនឆ្លងឱ្យមកនៅទាបដោយប្រើវិធានការចំនួន៤ រួមមាន វិធានការអប់រំវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការ ច្បាប់, **យុទ្ធសាស្ត្រទី៣**-ការខិតខំរកវិធី ព្យាបាលអ្នកជំងឺកាត់បន្ថយអ្នកស្លាប់រហូតឈានទៅដល់គ្មានអ្នកស្លាប់ដោយអនុវត្តនូវវិធានការចំនួន៥រួមមាន៖ ស្វះស្វែងរកប្រភពថ្នាំដែលមានប្រសិទ្ធភាពនិងតាមពិនិត្យមើលការផ្តល់ថ្នាំ ដែលមានការផ្តល់ខុសគ្នានៅតាមទីតាំងព្យាបាល, រៀបចំមន្ទីរពេទ្យបន្ថែមនៅតាមស្រុក និងបំពាក់សម្ភារៈឱ្យបានគ្រប់គ្រាន់នៅតាមពេទ្យខេត្ត និងស្រុក ជាពិសេសម៉ាស៊ីន ICU, ហ្វឹកហ្វឺន គ្រូពេទ្យបន្ថែម ដើម្បីចូលរួមបម្រើការងារប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩, ត្រូវបញ្ជាទិញសម្ភារៈឱ្យបានឆាប់ និងការដាក់ឱ្យព្យាបាលនៅតាមផ្ទះ, **យុទ្ធសាស្ត្រទី៤**-ការរុករក និងគ្រប់គ្រង។ យុទ្ធសាស្ត្រនេះ មានវិធានការចំនួន៥ រួមមាន៖ រៀបចំតំបន់យកសំណាក និងការយកសំណាកទៅពិនិត្យ, ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ និងខិតខំរកមេរោគបំប្លែងប្រភេទថ្មី, ពង្រីកការធ្វើតេស្តរហ័ស, រៀបចំការធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ រកឃើញហើយត្រូវទុកអ្នកជំងឺកន្លែងណា? ព្យាបាលកន្លែងណា? ឬឱ្យ នៅព្យាបាលតាមផ្ទះ និងតាមដានដោយបច្ចេកវិទ្យាព័ត៌មាន, **យុទ្ធសាស្ត្រ ទី៥-** ការរៀបចំកប់ ឬបូជាសពអ្នកជំងឺកូវីដ១៩ ឱ្យបានល្អតាមវិធានការ៤យ៉ាង៖ រៀបចំប៉ាឆាទៅកន្លែងមិនទាន់មានប៉ាឆា, ប្រើប៉ាឆាតាមវត្តតែត្រូវធានាសុវត្ថិភាពដោយធ្វើការជាមួយព្រះចៅអធិការវត្ត, រៀបចំដីសម្រាប់កប់សពតាមប្រពៃណីរបស់ជនជាតិភាគតិច និងខ្មែរ-ឥស្លាម និងរៀបចំផលិតក្តាមឈូសឱ្យបានត្រឹមត្រូវសម្រាប់យកទៅបូជា ឬកប់។ សម្តេចតេជោណែនាំឱ្យរដ្ឋមន្ត្រីក្រសួងកសិកម្ម រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងនាយឧត្តមសេនីយ៍ **សៅ សុខា** ប្រើប្រាស់ឈើខុសច្បាប់ដែលរឹបអូសបានយកមកធ្វើក្តាមឈូសជូនអ្នកស្លាប់ដោយកូវីដ និង**យុទ្ធសាស្ត្រ៦-** យុទ្ធសាស្ត្រវ៉ាក់សាំង ត្រូវរក៉ាក់សាំងការពារជំងឺកូវីដ១៩ ឱ្យបានយ៉ាងហោចណាស់ចាក់ជូនប្រជាពលរដ្ឋឱ្យបាន ១០លាននាក់ នៅជំហានដំបូង និងដល់ក្មេងអាយុក្រោម ១៨ឆ្នាំ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា នៅក្នុងយុទ្ធសាស្ត្រវ៉ាក់សាំងកម្ពុជាត្រូវបន្តយកចិនធ្វើជាបង្អែកយុទ្ធសាស្ត្រសម្រាប់ការផ្គត់ផ្គង់វ៉ាក់សាំង

ឯប្រភពផ្សេងទៀតគឺជាប្រភពគាំទ្រ។ សម្តេចតេជោបានបន្តថា ការសម្រេចចិត្តរបស់សម្តេចគឺត្រឹមត្រូវ អ្នកណាចង់ថាអីថាទៅ លើការជាក់-ស្តែងយើងនឹងទទួល់វ៉ាក់សាំងពីចិនជាង២០លានដូស។ ប្រសិនបើយើងមិនចាប់យកយុទ្ធសាស្ត្រនេះ យើងវិលទៅនេះបន្តិចវិលទៅនោះបន្តិចរង់ចាំបន្តិច សូម្បី ២០ ម៉ឺនដូសក៏មិនបានផងកុំថាឡើយ ៤ លានដូសព្រោះកូ៉ាក់ដែលបានសន្យាឲ្យយើង ៧ លានដូសបានមកតែ ៣២៤.០០០ ដូសប៉ុណ្ណោះ។ ៉ាក់សាំងនេះចាក់បានតែប្រមាណ ១៦ ម៉ឺននាក់តែប៉ុណ្ណោះ។ ខ្ញុះអីអ្នកសន្យាឲ្យសូរខ្លាំងណាស់សុទ្ធតែ ១៣ន់លានដូស ២៣ន់លានដូស ប៉ុន្តែវាអត់មានវ៉ាក់សាំង។ មានអ្នកធ្វើអត្ថាធិប្បាយថាកេរ្តឹ៍អាកររបស់**សម្តេចតេជោ ហ៊ុន សែន** គឺវ៉ាក់សាំង អ្នកឯងនិយាយត្រូវ។ សម្តេចតេជោបានលើកឡើងថា មិត្តបរទេសអាចយល់ពីចិត្តរបស់កម្ពុជា។ បើអស់លោកមិនផ្តល់ឲ្យខ្ញុំផងតើខ្ញុំទៅពឹងអ្នកណា? ខ្ញុំត្រូវការការពារប្រជាជនរបស់ខ្ញុំ។ មើលប្រទេសមួយចំនួនដែលពឹងពាក់ទៅលើប្រទេសដទៃក្រៅពីចិនបានវ៉ាក់សាំងហើយឬនៅ?។

សម្តេចតេជោ ហ៊ុន សែន ក៏បានលើកឡើងទៀតថា **យុទ្ធសាស្ត្រទី៣**-វ៉ាក់សាំងមកដល់ត្រូវផ្តល់ទៅកន្លែងអាទិភាព និងប្រមូលកម្លាំងចាក់ឲ្យបានរហ័សបើវ៉ាក់សាំង មកដល់អស់ត្រឹមខែ សីហា គឺខែ ១១ យើងអាចបញ្ចប់ការចាក់ជូនប្រជាជន១០ លាននាក់ ។ បន្ទាប់ទៅយើងបន្តគិតគូរទៅដល់ក្មេងអាយុពី ១៥ ឆ្នាំ ទៅ ១៧ ឆ្នាំសិនតើត្រូវការវ៉ាក់សាំងប៉ុន្មាន, ហើយបានគិតពីអាយុ ១៣ឆ្នាំ ទៅ ១៧ឆ្នាំដែលត្រូវការវ៉ាក់សាំងប៉ុន្មានហើយក្មេងដែលត្រូវអាយុ ១៨ ឆ្នាំផងដែរ ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងឲ្យដឹងទៀតថា នៅក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលទទួលបានថវិកាឧបត្ថម្ភសរុបជាង១៣០លានដុល្លារ។ ចំណូលដែលបានមកពីព្រះរាជឧបត្ថម្ភរបស់ព្រះមហាក្សត្រជាទីសក្តារៈដ៏ខ្ពង់ខ្ពស់ និងសម្តេចហ្លួងម៉ែ ក៏ដូចជាការឧបត្ថម្ភរបស់សប្បុរសជន បងប្អូនជនរួមជាតិមានរហូតដល់ ១២២.២៣៦.៥៧៥ ដុល្លារសហរដ្ឋអាមេរិក ក្នុងនោះជំនួយលើកទី១ គឺមាន ១០.៨៥៣.៤៨៨ដុល្លារ, លើកទី២ ចំនួន ៣៣.៧៣៤.៨៣០ដុល្លារ, លើកទី៣ សម្រាប់ទិញ៉ាក់សាំងចំនួន ៥៧.២៤៨.០៥៧ ដុល្លារ, លើកទី៤ ទិញមន្ទីរពេទ្យហ្លួងម៉ែ ចំនួន១៥.៤០០.៣០០ដុល្លារ, និងលើកចុងក្រោយសម្រាប់ទិញឧបករណ៍តេស្តរហ័ស ៥.០៥០.០០០ដុល្លារ ។ ក្រៅពីនោះ មានការបរិច្ចាគជាប្រាក់បៀវត្ស របស់បងប្អូនមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ ដែលមានទឹកប្រាក់ទទួលបានជាប្រាក់រៀលចំនួនជាង៥០៣ន់លានរៀល ដែលស្មើនឹងប្រមាណជាង ១២លានដុល្លារអាមេរិក។ សម្តេចតេជោប្រមុខរាជរដ្ឋាភិបាលបានបញ្ជាក់ថា «*បើយើងគិតទាំងការបរិច្ចាគពីព្រះមហាក្សត្រ សម្តេចហ្លួងម៉ែ ពីព្រះសង្ឆ ពីសប្បុរសជន ពីបងប្អូនជនរួមជាតិ ពីសំណាក់ មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ទទួលបានថវិកាប្រមាណជាង ១៣០លានដុល្លារសហរដ្ឋអាមេរិក។ នេះជាទឹកចិត្តដែលធ្វើឲ្យយើងបង្កើតបានជាចលនាជាតិប្រឆាំងនឹងកូវីដ១៩*»។ ក្នុងនោះ ប្រជាពលរដ្ឋជាង ៤០ម៉ឺនគ្រួសារត្រូវបានរាជរដ្ឋាភិបាលផ្តត់ផ្តង់ស្បៀងអាហារ អំឡុងពេលរាជរដ្ឋាភិបាលអនុវត្តវិធានការបិទខ្ទប់។ រាជរដ្ឋាភិបាលចំណាយមួយខែជាង ៤០លានដុល្លារ សម្រាប់ជួយដោះស្រាយការលំបាករបស់ប្រជាពលរដ្ឋប្រមាណ ៧០ម៉ឺនគ្រួសារ បូកនឹងកម្មករ និយោជិត ក្នុងវិស័យកាត់ដេរ និងទេសចរណ៍។

✵ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២១ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញថ្លែងសុន្ទរកថា នៅក្នុងកិច្ចប្រជុំកំពូលរវាងថ្នាក់ដឹកនាំនៃបក្សកុម្មុយនីស្តចិន និងគណបក្សនយោបាយលើពិភពលោកក្រោមប្រធានបទ **«ការបំពេញការងារដើម្បីសុភមង្គលប្រជា-ជន ៖ការទទួលខុសត្រូវរបស់គណបក្សនយោបាយ»**។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីឯកឧត្តម **ស៊ី ជិនភីង** អគ្គលេខានៃគណៈកម្មា-ធិការមជ្ឈិមបក្សកុម្មុយនីស្តចិន និងជាប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន និងថ្នាក់ដឹកនាំតំណាងគណបក្សនយោបាយជាច្រើនទៀត។

សម្តេចតេជោ ហ៊ុន សែន បានគូសបញ្ជាក់ថា ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយ ដែលតម្រូវឱ្យប្រទេស និងទាំងគណបក្សនយោបាយទាំងអស់នៅលើពិភពលោក រួបរួមគ្នាជាធ្លុងមួយ ដើម្បីបុព្វហេតុមនុស្សជាតិ។ ក្នុងស្មារតីនេះ សម្តេចតេជោបានចែករំលែកនូវទស្សនៈមួយចំនួន អំពីតួនាទីរបស់គណបក្សនយោបាយ ក្នុងការឆ្លើយតបទៅនឹងវិបត្តិសកលនេះ ដើម្បីគោលដៅនៃការលើកកម្ពស់សុភមង្គល វិបុលភាព និងសុខមាលភាពប្រជាជន ដែលរួមមាន ៖ **ទី១**-ការតម្កល់ខ្ពស់នូវអាយុជីវិត និងផលប្រយោជន៍ប្រជាជន និងការជ្រោងខ្ពស់សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដោយគោរពខ្ជាប់ខ្ជួននូវអធិបតេយ្យភាព និងឯករាជ្យជាតិនីមួយៗ។ គណបក្សនយោ-បាយទាំងអស់,ទោះជាមាននិន្នាការណាក៏ដោយ ត្រូវគិតពីប្រយោជន៍ជាតិ និងប្រជាជនជាធំ ដោយមិនត្រូវលុះទៅនឹងរបៀបវារៈនយោបាយ រយៈពេលខ្លីនៃការដណ្តើមអំណាចឱ្យខាងតែបានតាមគ្រប់មធ្យោបាយ ដោយមិនខ្វល់អំពីសន្តិភាព ស្ថិរភាព អធិបតេយ្យជាតិ និងសុខទុក្ខរបស់ប្រជាជននោះឡើយ។ ក្នុងកាលៈទេសៈពោរពេញដោយភាពប្រឈមដ៏ស្រួចស្រាលនេះ គណបក្សនយោបាយ គួរតែប្រកាន់យកនូវការទទួលខុសត្រូវខ្ពស់ចំពោះជាតិ និងប្រជាជន ព្រមទាំងបញ្ឈប់ឱ្យបាននូវវប្បធម៌ និងឥរិយាបទច្រណែនឈ្នានីស ចាំតែមើលបំណាំ ចោទប្រកាន់ និងរិះគន់គ្មានមូលដ្ឋាន ដោយជំនួសមកវិញនូវឥរិយាបថបែបស្ថាបនានិយម និងស្មារតីនៃកិច្ចសហការក្នុងការដោះស្រាយបញ្ហាប្រឈមរបស់មនុស្សជាតិ និងប្រជាជន, ទាំងក្នុងក្របខណ្ឌពិភពលោក ក៏ដូចជាក្នុងប្រទេសនីមួយៗ។ **ទី២**-ការរួបរួមគ្នាសង្ត្រោះអាយុជីវិតមនុស្សជាតិ តាម រយៈការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ឱ្យបានជោគជ័យ។ គន្លឹះដ៏សំខាន់មួយនៅកិច្ចប្រឹងប្រែងដើម្បីគោលដៅនេះ គឺការចែករំលែក៉ាក់សាំង និងការចាត់ទុក៉ាក់សាំងជាទំនិញសាធារណៈ ដោយប្រកាន់យកនូវគោលការណ៍ **«វ៉ាក់សាំងពហុភាគីនិយម»** ទាំងក្នុងដំណើរការផលិត ចែកចាយ និងប្រើប្រាស់ ។ សម្តេចតេជោបានសម្តែងនូវអំណរ គុណយ៉ាងជ្រាលជ្រៅចំពោះសាធារណ-រដ្ឋប្រជាមានិតចិន ដែលបានយកចិត្តទុកដាក់ជួយគាំទ្រយ៉ាងក្លៀវក្លាដល់កម្ពុជា តាមរយៈការផ្តល់ជំនួយ, ទាំងផ្នែកបច្ចេកទេស និងសម្ភារៈ, និងជាពិសេស ជំនួយជា ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ព្រមទាំងការជួយសម្របសម្រួល និងការផ្តល់អាទិភាពដល់កម្ពុជា ចំពោះរាល់ការបញ្ជាទិញ៉ាក់សាំង ក្នុងស្មារតីមិត្តភាព និងសាមគ្គីភាព ដោយឥតលក្ខខណ្ឌដូចពាក្យ ស្លោកថា **«មិត្តល្អ ជួយគ្នាក្នុងគ្រាមានអាសន្ន»** និង**ទី៣**-នៅពេលដែលវិបត្តិនៃជំងឺកូវីដ-១៩ ថមថយនាពេលខាងមុខ ការគិតគូរទៅលើការងើបឡើងវិញនៃសង្គមសេដ្ឋកិច្ច គឺជាកិច្ចការមួយដ៏សំខាន់

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញទទួល ដោយផ្ទាល់នូវការមកដល់វ៉ាក់សាំងជំងឺកូវីដ-១៩ ដែលជាជំនួយរបស់រដ្ឋាភិបាល និងប្រជាជនជប៉ុន

មិនអាចខ្វះបាន ។ ប្រការនេះ នឹងទាមទារឱ្យមានការលើកកម្ពស់យន្តការទ្វេភាគី និងពហុភាគីនិយមផ្សេងៗ ដូចជា គំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ ដែលជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ឈ្នះ-ឈ្នះមួយដ៏សំខាន់ ក្នុងការលើកកម្ពស់សង្គមសេដ្ឋកិច្ច និងវិបុលភាពនៃប្រទេសនៅក្នុងតំបន់ និងពិភពលោកតាមរយៈការជំរុញហ៊ូរពាណិជ្ជកម្មនិងការវិនិយោគ ។ឆ្លៀតក្នុងឱកាសនេះ សម្តេចតេជោបានសម្តែងជាថ្មីម្តងទៀត នូវការគាំទ្រយ៉ាងមុតមាំចំពោះ **«គំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ»** ដែលនឹងនាំមកនូវវិបុលភាព និងសុភមង្គល ជូនដល់ប្រជាជននៅក្នុងបណ្តាប្រទេស និងតំបន់ ស្ថិតក្រោមវិសាលភាពនៃគំនិតផ្តួចផ្តើមនេះ នៅក្នុងបរិបទនៃការងើបឡើងវិញនៃសង្គម-សេដ្ឋកិច្ច ក្រោយពីវិបត្តិនៃជំងឺកូវីដ-១៩ បានស្រាកស្រាន្ត ។

នៅក្នុងឱកាសនោះ **សម្តេចតេជោ ហ៊ុន សែន** បានសង្កត់ធ្ងន់ថា ជំនួយរបស់ចិននេះមិនត្រឹមតែជួយដល់ការអភិវឌ្ឍនិងធ្វើឱ្យកម្ពុជាងើបចេញពីភាពក្រីក្រប៉ុណ្ណោះទេ តែក៏បានជួយពង្រឹងដល់ឯករាជ្យភាពរបស់កម្ពុជាផងដែរ ។ **សម្តេចតេជោ ហ៊ុន សែន** ក៏ជំរុញឱ្យគណបក្សនយោបាយទាំងអស់រួមគ្នាប្តេជ្ញារក្សាស្ថិរភាពនយោបាយ និងរារាំងឱ្យបានដាច់ខាតនូវការជ្រៀតជ្រែកនយោបាយពីប្រទេសដទៃ ។ សម្តេចតេជោក្នុងនាមប្រធានគណបក្សប្រជាជន បានសង្កត់ធ្ងន់ថា គណបក្សនយោបាយទាំងអស់ ទោះជាមាននិន្នាការណាក៏ដោយ ត្រូវគិតពីប្រយោជន៍ជាតិ និងប្រជាជនជាធំ ដោយមិនត្រូវឱនក្បាលធ្វើជាឈ្នាន់នយោបាយ និងវិទ្ធង្សនារបស់បរទេស បើទោះបីជាស្ថិតក្រោមរូបភាពណាក៏ដោយ ។ គណបក្សនយោបាយទាំងអស់អាចបញ្ឈប់បាននូវប្បាធម៌និងឥរិយាបថច្រណែនឈ្នានីស ចាំតែមើលបំណាំ ចោទប្រកាន់ និងរិះគន់គ្មានមូលដ្ឋាន ដោយជំនួសមកវិញនូវឥរិយាបថបែបតថភាពនិយម ប្រាកដនិយម និងប្រកាន់ខ្ជាប់នូវស្មារតីនៃការសហការគ្នា ក្នុងការដោះស្រាយរាល់បញ្ហារបស់មនុស្សជាតិទាំងក្នុងក្របខណ្ឌពិភពលោក និងក្នុងប្រទេសនីមួយៗ ។

សម្តេចតេជោ ហ៊ុន សែន ក៏បានរំលឹកពីការរួមចំណែករបស់ចិនជួយដល់ការពង្រឹងនូវឯករាជ្យភាពរបស់កម្ពុជា តាមរយៈការផ្តល់ជំនួយផ្សេងៗផងដែរ ។ សម្តេចតេជោ បានថ្លែងថា **"ខ្ញុំគួរតែបញ្ជាក់ឱ្យបានច្បាស់ថា ជំនួយរបស់ចិនមកដល់កម្ពុជា មិនគ្រាន់តែជួយទៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រប៉ុណ្ណោះទេ ក៏ប៉ុន្តែវាបានជួយកម្ពុជាក្នុងការពង្រឹងនូវឯករាជ្យភាពខាងនយោបាយទៀតផង ។ វាច្បាស់ណាស់ថា ប្រទេសតូចតាច និងប្រទេសក្រីក្រត្រូវការចាំបាច់នូវឯករាជ្យ និងអធិបតេយ្យភាពចៀសវាងនូវការបង្ហាប់បញ្ជា និងការជ្រៀតជ្រែកពីខាងក្រៅ"** ។

❋ នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១ **អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញដឹកនាំកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីតាមប្រព័ន្ធអនឡាញ (Zoom) ដែលនៅក្នុងកិច្ចប្រជុំនោះ **សម្តេចតេជោ ហ៊ុន សែន** បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលនឹងបន្តទិញវ៉ាក់សាំងកូវីដ-១៩ និងសម្រេចបន្តការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋកម្ពុជាឱ្យបានតាមផែនការកំណត់ ព្រមទាំងពិចារណាការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋដូសទី៣ និងក្រោមអាយុ ១៨ឆ្នាំ ។ សម្តេចតេជោក៏បានអំពាវនាវដល់គ្រប់ក្រសួងស្ថាប័ន ត្រូវយកចិត្តទុកដាក់ក្នុងការប្រើប្រាស់ឧបករណ៍តេស្តរហ័សដោយសន្សំសំចៃ និងប្រើថវិកាសន្សំដើម្បីទិញឧបករណ៍តេស្តរហ័សសម្រាប់ប្រើប្រាស់នៅក្នុងសាមីក្រសួងស្ថាប័ន ។ ជាមួយគ្នានេះ រដ្ឋបាលខេត្តនៅតាមព្រំដែន និងអនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក ត្រូវយកចិត្តទុកដាក់ពង្រឹងសមត្ថភាពការធ្វើចត្តាឡីស័កចំពោះពលករ និងប្រជាពលរដ្ឋដែលឆ្លងដែនចូលព្រះរាជាណាចក្រកម្ពុជាឱ្យបានម៉ត់ចត់ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ បំប្លែងថ្មី DELTA ដ៏កាចសាហាវកុំឱ្យឆ្លងចូលមកក្នុងសហគមន៍ ។ សម្តេចតេជោក៏បានជំរុញឱ្យគ្រប់ក្រសួងស្ថាប័នត្រូវអនុវត្តការងារតាមប្រព័ន្ធអនឡាញ ដើម្បីធានារក្សាប្រក្រតីភាព ការងារ និងចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ។

❋ នៅព្រឹកថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញថ្លែងសារពិសេសពាក់ព័ន្ធនឹងដំណើរការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនដល់កុមារ និងយុវវ័យចាប់ពីអាយុ១២ដល់១៧ឆ្នាំតាមប្រព័ន្ធវីដេអូ ។ សម្តេចតេជោបានថ្លែងថា យើងមានការចាំបាច់ ដើម្បីចាក់ជូនកុមារ និងយុវវ័យអាយុ១២ដល់អាយុ១៧ឆ្នាំបន្តទៀតបន្ទាប់ពីដំណើរការចាក់វ៉ាក់សាំងសម្រាប់អ្នកដែលមានអាយុពី ១៨ឆ្នាំឡើងទៅ ។ **សម្តេចតេជោ ហ៊ុន សែន** បានគូសបញ្ជាក់ថា ដោយមានការគិតគូរយ៉ាងម៉ត់ចត់ ទៅលើបរិយាកាសភាពសុំាក្នុងសង្គម និងគិតគូរទៅដល់អនាគតរបស់កុមារ និងយុវជនជាពិសេស ការផ្តោតការយកចិត្តទុកដាក់ទៅលើសុខភាព ពាក់ព័ន្ធនឹងការបើកឡើងវិញនូវសាលារៀនដែលជាការបាត់បង់យ៉ាងធំធេងរបស់ពិភពលោក ក៏ដូចជាប្រទេសកម្ពុជាផងដែរ គឺការបណ្តុះបណ្តាលធនធានមនុស្ស ដែលសាលារៀនត្រូវបានបិទ ក្នុងរយៈពេលយូរ ដូច្នេះយើងមានតម្រូវការការចាក់វ៉ាក់សាំងសម្រាប់កុមារ និងយុវវ័យ ចាប់ពីអាយុ១២ ដល់អាយុ ១៧ឆ្នាំ ។ សម្តេចតេជោក៏បានអំពាវនាវដល់មាតាបិតាអាណាព្យាបាលកុមារត្រៀមខ្លួនដើម្បីនាំកូន នាំចៅទៅចាក់វ៉ាក់សាំងនៅពេលវេលាដែលបានមកដល់ ។ យើងចង់ឱ្យមានភាពសុំានៅក្នុងសង្គម ដើម្បីឈានទៅដល់ការបើកវិញនូវសង្គមសេដ្ឋកិច្ចពិសេសគឺសាលារៀនដែលយើងបានបិទសាលា ហើយឱ្យរៀនពីចម្ងាយតាមរយៈប្រព័ន្ធអនឡាញ ។ រឿងនេះជាការខាតបង់មួយសម្រាប់យើង ។ បើសិនយើងបាន

ចាក់វ៉ាក់សាំងឱ្យកុមារ និងយុវជន យ៉ាងហោចណាស់យើងអាចបើកសាលាចាប់ពីអនុវិទ្យាល័យឡើងទៅ ។

❋ នៅរាត្រីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទទួលដោយផ្ទាល់នូវការមកដល់វ៉ាក់សាំងជំងឺកូវីដ-១៩ ដែលជាជំនួយរបស់រដ្ឋាភិបាល និងប្រជាជនជប៉ុន នៅអាកាស យានដ្ឋានអន្តរជាតិភ្នំពេញ។ **សម្តេចតេជោ ហ៊ុន សែន** សម្តែង អំណរគុណដល់រាជរដ្ឋាភិបាល ក៏ដូចជាប្រជាជនជប៉ុនដែលតែងតែជួយដល់ប្រទេសកម្ពុជា ជាពិសេសអរគុណចំពោះការផ្តល់អំណោយជាវ៉ាក់សាំង១លានដូសនាពេលនេះសម្រាប់រដ្ឋាភិបាល ក៏ដូចជាប្រជាជនកម្ពុជាដើម្បីទប់ ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩។

ក្នុងឱកាសនោះ **សម្តេចតេជោ ហ៊ុន សែន** បានធ្វើការឆ្លើយតបទៅមនុស្សមួយចំនួនដែលបានធ្វើអត្ថាធិប្បាយថា ប្រហែលជាមរតកធំបំផុតរបស់ហ៊ុនសែនគឺវ៉ាក់សាំង ។ **សម្តេចតេជោ ហ៊ុន សែន** បានគូសបញ្ជាក់ថា មរតក ហ៊ុន សែន មិនមែនមានត្រឹមតែវ៉ាក់សាំងនោះទេ ,មរតក ហ៊ុន សែន គឺ បានរំដោះប្រជាជនចេញពីការស្លាប់នៅថ្ងៃទី ខែ៧ មករា ឆ្នាំ១៩៧៩, មរតក ហ៊ុន សែន ក៏បានយកប្រជាជនកម្ពុជាចេញផុតពីសង្គ្រាមនាំមកនូវសន្តិភាព និងការអភិវឌ្ឍរហូតដល់សព្វថ្ងៃ, មរតក ហ៊ុន សែននៅមានច្រើនទៀត... ។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងបន្តទៀតថា៖ ខ្ញុំមិនចង់បានមរតក ឬមិនមរតកទេ ប៉ុន្តែអ្វីដែលសំខាន់សម្រាប់ខ្ញុំ គឺសុខុមាលភាពរបស់ប្រជាជន។ ជីវិតរបស់ប្រជាជនត្រូវបានជានា ហើយជីវិតដំបូងបំផុតមិនមែនសិទ្ធិបញ្ចេញមតិប្រជាធិបតេយ្យនោះទេគឺសិទ្ធិរស់រានមានជីវិតដែលគួរទទួលបានមុនគេ។ ដូច្នេះទោះបីអ្នកណាចង់និយាយអ្វីក៏និយាយទៅ...តែច្បាប់កម្ពុជាធ្វើគឺដើម្បីការពារជីវិតមនុស្ស។ អ្នកចង់និយាយពីអ្វីគឺ អ្នកនិយាយតាមចិត្តចង់របស់ អ្នកទៅ ប៉ុន្តែអ្វីដែលខ្ញុំបានកំពុងធ្វើគឺការពារជីវិតប្រជាជនកុំឲ្យស្លាប់» ។ សម្តេចតេជោបន្តទៀតថា ទោះបីយើង ខិតខំការពារក៏ប៉ុន្តែ យើងមិនអាចឃាត់មនុស្សមិនឲ្យស្លាប់បានទេ រាប់ទាំងខ្លួនខ្ញុំផងដែរ ដូច្នេះការរៀបចំក្តាមឈូសដែលគេចាត់ទុកថា ជាការប្រមាថ តែខ្ញុំចាត់ទុកថាជាការគោរពរបស់ខ្ញុំចំពោះសាកសពទាំងឡាយដែលបានស្លាប់ដោយកូវីដ-១៩ ។ ខ្ញុំមិនចង់ឃើញប្រជាជនកម្ពុជាណាម្នាក់នៅពេល ដែលទទួលមរណៈភាពដោយកូវីដ១៩ បែរជាត្រូវរុំនឹងកន្ទេលហើយយកទៅកប់ដោយគ្មានក្តាមឈូស ឬយក ទៅដុតដោយគ្មានក្តាមឈូសនោះទេ។ ខ្ញុំចង់បញ្ជាក់ថា ខ្ញុំមិនបានប្រមាថជីវិតប្រជាជនទេ។ **សម្តេចតេជោ ហ៊ុន សែន** បានបន្តថា នៅក្នុងសង្គមខ្មែរយើងមនុស្សចាស់ច្រើនណាស់ដែលធ្វើក្តារមឈូសខ្លួនឯងទុក ដើម្បីពេលដែលស្លាប់ទៅមានក្តាមឈូសស្រាប់។ ដូច្នេះ ខ្ញុំមិនមានកំហុសទៅលើបញ្ហាការរៀបចំឱ្យមានកន្លែងបញ្ចុះសាកសពមានប៉ាឆាសម្រាប់ជុត និងមានក្តាមឈូសសម្រាប់សាកសព ។

ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចតេជោ ហ៊ុន សែន** បានគូសបញ្ជាក់ថា ទោះដោយតម្លៃណាក៏ដោយរាជរដ្ឋាភិបាលត្រូវតែសម្រេចឲ្យបាននូវការចាក់វ៉ាក់សាំងជូនប្រជាជនកម្ពុជាដែលដល់អាយុត្រូវចាក់ ហើយដែលពេទ្យអនុញ្ញាតឲ្យចាក់។ ពិភពលោក ក៏ដូចកម្ពុជានៅសង្ឃឹមតែលើការណីវ៉ាក់សាំងនេះប៉ុណ្ណោះ។ យើងក៏បានមើលឃើញសញ្ញានៃការថមថយចុះ ជាពិសេសនៅក្នុងតំបន់រោងចក្រនៅទីក្រុងភ្នំពេញមានការថយចុះនៃការឆ្លង ហើយក្នុងករណីដែលមានការឆ្លងក៏មានស្ថានភាពមិនរុញទៅរកជំងឺធ្ងន់ធ្ងរដល់ការស្លាប់នោះទេ វាអាចកាត់បន្ថយការស្លាប់ ។ **សម្តេចតេជោ ហ៊ុន សែន** ថ្លែងថា នៅពេលយើងមានវ៉ាក់សាំងគ្រប់គ្រាន់នៅទីកន្លែងមួយចំនួន យើងអាចចាក់ទាំងមនុស្សចាស់ផង យើងចាក់ទាំងកូនក្មេងផងទៅជាមួយគ្នា។ យើងបានគិតគូរថានៅពេលដែលយើងកំពុងដាក់ផែនការចាក់វ៉ាក់សាំង ដែលយើងចាក់បាន ៦៥,៥៣ ចំនួនប្រជាជនដែលត្រូវចាក់ ១០ លាននាក់យើងនឹងចាក់បាន៦២,៥% នៃប្រជាជន ១៦លាននាក់ ។ ប្រសិនជាយើងចាក់ចំពោះកូនក្មេងអាយុ ១២ ដល់ ១៧ ឆ្នាំ ដែលយើងប៉ាន់ស្មានថាមានប្រមាណ២លាននាក់នោះក្នុងចំនួន១២ លាននាក់ យើងមានប្រជាជនដែលត្រូវចាក់វ៉ាក់សាំង ៦៥% ប៉ុន្តែនៅពេលដែលយើងអាចនឹងមានប្រជាជនច្រើនជាងនេះហើយអាចនឹងមានករណីចាក់ក្នុងអាយុ ក្រោម១២ឆ្នាំបន្តទៀត យើងគិតត្រឹម ១៣ លាននាក់ យើងនឹងចាក់បាន ៨២,២៥ % នៃចំនួនប្រជាជនអាចចាត់ទុក ថាជាការអាចសុំាបាន ។ **សម្តេចតេជោ ហ៊ុន សែន** ក៏បានផ្តាំផ្ញើទៅមាតាបិតាអាណាព្យាបាលនាំកូនចៅទៅចាក់ឲ្យបានគ្រប់គ្នា ព្រោះវាគ្មាន អ្វីចម្លែកនោះទេ បើប្រៀបធៀបទៅនឹងទារក និងកុមារដែលបានទទួលវ៉ាក់សាំងជាបន្តបន្ទាប ដើម្បីការពារជំងឺច្រើនមុខដែលគេចាប់ផ្តើម ទទួលវ៉ាក់សាំងតាំងពីកើត។ ដូច្នេះសូមកុំមានការបារម្ភវាគ្មានហានិភ័យណាមួយកើតឡើង សម្រាប់ការចាក់វ៉ាក់សាំងនោះទេ។ សម្តេចតេជោ នាយករដ្ឋមន្ត្រី បានជំរុញឱ្យក្រសួងពាក់ព័ន្ធបន្តអនុវត្តវិធានការសុខាភិបាល និងរួមគ្នាប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩បន្តទៀត និងអំពាវនាវដល់ប្រជាពលរដ្ឋឱ្យបន្តអនុវត្តវិធានការសុខាភិបាល ដើម្បីរួមគ្នាទប់ស្កាត់ជំងឺកូវីដ១៩ និងស្រោចស្រង់សង្គមកម្ពុជាឡើងវិញនាពេលខាងមុខ។

គួរបញ្ជាក់ថា រដ្ឋាភិបាលជប៉ុន កាលពីថ្ងៃទី១៣ ខែកក្កដា កន្លងទៅនេះ បានប្រកាសផ្តល់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ អាស្ត្រាហ្សេនីកា (AstraZeneca) ចំនួន ១លានដូស ដល់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ហើយនៅរាត្រីនេះ វ៉ាក់សាំងជំនួយរបស់ជប៉ុន ដែលដឹកមកកម្ពុជានាពេលនេះ មានចំនួន ៣៣ម៉ឺនដូស ហើយចំនួននៅសល់នឹងដឹកមកជាបន្តបន្ទាប់ទៀត។ ឯកឧត្តម **មិកាមិ ម៉ាសាហ៊ីរ៉ូ** (MIKAMI Masahiro) ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា បានថ្លែងថា ការផ្តល់ជំនួយវ៉ាក់សាំង ចំនួន ១លានដូស នេះធ្វើឡើងស្របតាមចំណងមិត្តភាពរវាង ជប៉ុន និងកម្ពុជា និងដោយផ្អែកលើស្ថានភាពកូវីដ១៩ នៅកម្ពុជានាពេលបច្ចុប្បន្ន។ ឯកឧត្តម បានបង្ហាញក្តីសង្ឃឹមថា ជំនួយវ៉ាក់សាំងនេះ នឹងជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងកូវីដ-១៩ ក៏ដូចជាកាត់បន្ថយការព្រួយបារម្ភមួយចំនួនរបស់ប្រជាជនកម្ពុជា។ ឯកអគ្គរាជទូត បានគូសបញ្ជាក់ថា ក្នុងការប្រយុទ្ធប្រឆាំងនឹងកូវីដ-១៩ ដែលជាបញ្ហាពិភពលោកនេះ ជប៉ុននឹងបន្តសហការ និងធ្វើការរួមគ្នាជាមួយកម្ពុជាដែលជាមិត្តដ៏សំខាន់ ៕

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ដឹកនាំកិច្ចប្រជុំ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

សម្តេចចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតី ដ៏ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការ អចិន្ត្រៃយ៍រដ្ឋសភា តាមប្រព័ន្ធវីដេអូ



នាព្រឹកថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាតាមប្រព័ន្ធវីដេអូដើម្បីអនុម័តរបៀបវារៈមួយ ចំនួន។ ជាលទ្ធផលកិច្ចប្រជុំបានសម្រេចទទួលយកសេចក្តីព្រាងច្បាប់ចំនួន៣ ដែលស្នើឡើងដោយរាជរដ្ឋាភិបាលប្រគល់ជូនគណៈ កម្មការជំនាញរដ្ឋសភាពិនិត្យសិក្សា ព្រមទាំងបានអនុម័តបញ្ចូលសេចក្តីព្រាងច្បាប់ ដែលគណៈកម្មការជំនាញរដ្ឋសភាបានពិនិត្យសិក្សារួចហើយនាពេលកន្លងមកចំនួន ៤ ដើម្បីដាក់ទៅក្នុងរបៀបវារៈសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ដែលនឹងប្រព្រឹត្តិទៅនាពេលខាងមុខ។

សេចក្តីព្រាងច្បាប់ថ្មីចំនួន៣ ដែលរដ្ឋសភាសម្រេចទទួលយកមកពិនិត្យសិក្សាតាមសំណើរបស់រាជរដ្ឋាភិបាលរួមមាន៖ **១**- សេចក្តីព្រាងច្បាប់ស្តីការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានបូកបីស្តីពីការត្រៀមបម្រុងអង្ករសង្គ្រោះបន្ទាន់, **២**- សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពីការងារ និង**ទី៣**- សេចក្តីព្រាងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

ចំណែកសេចក្តីព្រាងច្បាប់ចំនួន៤ ដែលគណៈកម្មការជំនាញរដ្ឋសភាបានពិនិត្យ និងសិក្សារួចរាល់ ត្រូវបានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបានអនុម័តបញ្ចូលក្នុងរបៀបវារៈសម្រាប់សម័យប្រជុំរដ្ឋសភាលើកទី៦នីតិកាលទី៦ នាពេលខាងមុខ។ សេចក្តីព្រាងច្បាប់ទាំងនោះ រួមមាន៖ **១**- សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់, **២**- សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្ម មាត្រា១៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា, **៣**- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និងទី៤- សេចក្តីព្រាងច្បាប់ស្តីការប្រកួតប្រជែង។

នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាក៏បានអនុម័តជ្រើសតាំង ឯកឧត្តម **ម៉ែន ភួន** ជាសមាជិកគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា ដើម្បីដាក់ជូនសម័យប្រជុំរដ្ឋសភា នាពេលខាងមុខបន្តនីតិវិធីផងដែរ៕

សម្តេចក្រឡាហោម ស ខេង ៖ បើមានបញ្ហាប៉ះពាល់ដល់ផលប្រយោជន៍ និងសិទ្ធរបស់ប្រជាជនត្រូវធ្វើការដោះស្រាយភ្លាម

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីក្នុងពិធី ប្រកាសចូលកាន់តំណែង

នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសចូលកាន់តំណែង ឯកឧត្តម **ស៊ុន សុវណ្ណារិទ្ធិ** ជាអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំងថ្មី ជំនួសឯកឧត្តម **ឈួរ ច័ន្ទឌឿន** ។

ក្នុងឱកាសនោះ **សម្តេចក្រឡាហោម ស ខេង** បានថ្លែងថា រាល់ការសម្រេចចិត្តក្នុងការតែងតាំងសុទ្ធតែផ្អែកលើទិដ្ឋភាពច្បាប់ជាធំ ពោលគឺមិនមែនជាការសម្រេចតាមការស្រមើស្រមៃ ឬនឹកឃើញចេះតែលើកដាក់នរណាម្នាក់ឱ្យធ្វើនោះទេ ពីព្រោះកិច្ចការនេះទាក់ទងនឹងដោគ-វាសនាប្រទេសជាតិ ដោគវាសនាប្រជាពលរដ្ឋ ដោយមិនអាចយកមនោ-សញ្ចេតនាណាមួយមកលាយឡំនឹងផលប្រយោជន៍ជាតិនិងផលប្រយោជន៍ប្រជាពលរដ្ឋបានឡើយ។ ប្រសិនបើធ្វើដូច្នេះមែន រាជរដ្ឋាភិបាលមិនអាចគ្រប់គ្រងប្រទេសប្រកបដោយសេចក្តីសុខ និងរីកចំរើនដូចសព្វថ្ងៃនេះទេ។

សម្តេចក្រឡាហោម ស ខេង បានផ្តល់អនុសាសន៍ឱ្យរដ្ឋបាលខេត្តបន្តថែរក្សា និងពង្រឹងសន្តិភាព ស្ថិរភាព នយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីបង្កបរិយាកាស អំណោយផលដល់ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ។ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវពង្រឹងការគ្រប់គ្រងសភាពការណ៍តាមមូលដ្ឋាន ដើម្បីដាក់ចេញវិធានការទប់-ស្កាត់ឱ្យបានទាន់ពេលវេលានូវសកម្មភាព ការផ្សព្វផ្សាយ ព័ត៌មានមិនពិត និងភាពចលាចល ពិសេសសកម្មភាពប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់។ អាជ្ញាធរគ្រប់ថ្នាក់ គ្រប់ផ្នែកត្រូវយកចិត្តទុកដាក់អប់រំប្រជាពលរដ្ឋឱ្យចូលរួមគោរពច្បាប់ ការពារផលប្រយោជន៍សាធារណៈ ផល-ប្រយោជន៍សហគមន៍ និងចៀសវាងការចូលរួមក្នុងសកម្មភាពផ្ទុយពីច្បាប់ដែលធ្វើឱ្យប៉ះពាល់ដល់សន្តិភាពនិងស្ថិរភាពនយោបាយព្រមទាំងយកចិត្តទុកដាក់ដោះស្រាយជម្លោះ នៅមូលដ្ឋានឱ្យបានល្អដោយចៀសវាង ឱ្យបាននូវការប្រើប្រាស់អំពើហិង្សាគ្រប់រូបភាព។

សម្តេចក្រឡាហោមក៏បានគូសបញ្ជាក់ទៀតថា នៅឆ្នាំក្រោយ គឺជាឆ្នាំនៃព្រឹត្តិការណ៍បោះឆ្នោត ដែលអ្នកនយោបាយផ្សេងៗអាចយកបញ្ហាប្រឈម និងទំនាស់នានាក្នុងមូលដ្ឋានធ្វើះក្នុងបំណងទាញប្រជាប្រិយភាព ដូច្នេះអាជ្ញាធរនិងសមត្ថកិច្ចទាំងអស់ត្រូវតែយកចិត្តទុកដាក់ពីឥឡូវទៅដើម្បីគ្រប់គ្រង សភាពការណ៍ ហើយដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋឱ្យបានល្អ ដោយមិនត្រូវមានទស្សនៈខុសឆ្គងថាបញ្ហាទាំងនោះ គឺដោយសារមានពួកប្រឆាំង ឬដោយសារបញ្ហានេះ បញ្ហានោះទេ ឡើយ សំខាន់ត្រូវមើលខ្លួនឯង ថាតើមាន បញ្ហាមែនដែរឬទេ មានប៉ះពាល់សិទ្ធិ និងផលប្រយោជន៍ប្រជាពលរដ្ឋឬទេ ហើយបើមានត្រូវដោះស្រាយ ភ្លាម។

សម្តេចក្រឡាហោម បានណែនាំឱ្យមន្ត្រីទាំងអស់ខិតខំជំរុញការអនុវត្តគោលនយោបាយភូមិឃុំសង្កាត់មានសុវត្ថិភាពទាំង៧ចំណុច រួមមានការផ្តល់សេវាសាធារណៈជាពិសេសសេវារដ្ឋបាល ប្រកបដោយគុណភាព តម្លាភាព និងប្រកបដោយការជឿទុកចិត្ត, គ្មានបទល្មើសលួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើស គ្រប់ប្រភេទ, មានសណ្តាប់ធ្នាប់សាធារណៈល្អ ពិសេសគ្មានគ្រោះថ្នាក់ ចរាចរណ៍, គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសការជួញដូរស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង, ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព, មានអនាម័យ មានសោភណ្ឌភាពល្អ និងចុងក្រោយ គឺត្រូវឆ្លើយតបបានទាន់ពេលវេលា ចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតប្រកបដោយប្រសិទ្ធភាព។

ពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន សម្តេចក្រឡាហោមបានបញ្ជាក់ថា «ការជួញដូរការចែកចាយការប្រើប្រាស់គ្រឿងញៀនខុសច្បាប់បាននិងកំពុង បង្កឱ្យមានបញ្ហាប្រឈមជាច្រើនក្នុងសង្គម ដែលត្រូវដោះស្រាយក្នុងរយៈពេលចំពោះមុខ និងរយៈពេលយូរអង្វែង ។ហេតុនេះត្រូវខិតខំពុះពារជម្នះប្រកបដោយធន្ធនៈនយោបាយ និងការប្តេជ្ញាចិត្តឱ្យបានមុតមាំដើម្បីអនុវត្តវិធានការនានាក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដោយចាត់ទុកយុទ្ធនាការនេះជាផ្នែកមួយនៃការលើកម្ពស់យុត្តិធម៌សង្គម, ជាផ្នែកមួយនៃការប្រយុទ្ធប្រឆាំងនឹងបទល្មើសសម្អាតប្រាក់ និងការរីក-សាយអាវុធមហាប្រល័យ, ជាផ្នែកមួយនៃការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម និងឧក្រិដ្ឋកម្មគ្រប់ប្រភេទ, ជា ផ្នែកមួយនៃការកាត់ផ្តាច់ទំនាក់ទំនងរបស់ក្រុមសង្គមងងឹតពីខាងក្រៅ និង មកខាងក្នុងប្រទេស និងទប់ស្កាត់ការកើតក្រុមសង្គមងងឹតក្នុងប្រទេស, ជា ផ្នែកមួយនៃការលើកកម្ពស់សុខភាព និងសុខមាលភាពប្រជាពលរដ្ឋដែលជា ធនធានដ៏មាន តម្លៃសម្រាប់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាពរយៈពេល យូរអង្វែងតទៅមុខទៀត ជាពិសេសយុវជន, ជាផ្នែកមួយនៃការធ្វើមានបរិយាកាសសុខសន្តិភាព ស្ថេរភាព និងសណ្តាប់សាធារណៈ, ជាផ្នែកមួយ នៃការបង្កើនភាពកក់ក្តៅ និងភាពសុខដុមរមនានៅក្នុងក្រុមគ្រួសារប្រជាពលរដ្ឋក្នុងសង្គម និងជាផ្នែកមួយនៃការចូលរួមធនធានសង្គមដូចជាថវិកាជាតិ និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ»។

សម្តេចក្រឡាហោម ក៏បានណែនាំឱ្យរដ្ឋបាលខេត្តបន្តចូលរួមឱ្យបានសកម្ម និងប្រកបដោយប្រសិទ្ធភាពក្នុងការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដែល កំពុងឆ្លងរាតត្បាតផងដែរ៕

សម្តេចវិបុលសេនាភក្តី សាយ ឈុំ អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំបន្តសម័យប្រជុំលើកទី៧ ព្រឹទ្ធសភា នីតិកាលទី៤

សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតី ដ៏ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីបន្តសម័យប្រជុំលើកទី៧ ព្រឹទ្ធសភា នីតិកាលទី៤ នៅវិមានព្រឹទ្ធសភា។ សម័យប្រជុំលើកទី៧ ព្រឹទ្ធសភា នីតិកាលទី៤ នេះមានរបៀបវារៈមួយចំនួនរួមមាន៖ **១**-ស្តាប់របាយការណ៍របស់គណៈកម្មការធិការអចិន្ត្រៃយ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៧ នីតិកាលទី៤, **២**-ពិនិត្យនិងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី សម្រាប់គម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គីសនី តង់ស្យុង៥០០ គីឡូវ៉ុលពី ខេត្តបាត់ដំបង ទៅកាន់ព្រំដែន កម្ពុជា-ថៃ, **៣**- ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាល នៃរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុនស្នេថេក ខូអិលធីឌី សម្រាប់គម្រោងអភិវឌ្ឍន៍ខ្សែបណ្តាញបញ្ជូនអគ្គីសនី តង់ស្យុង ៥០០គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅកាន់ព្រំដែនកម្ពុជា-ឡាវ, **៤**- ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុនអគ្គីសនីវៀតណាម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម សម្រាប់ជានាលើការទិញថាមពលអគ្គីសនីពីប្រទេសវៀតណាម និង**៥**-ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឲ្យក្រុមហ៊ុនឆាយណា ណេសិនណល ហៅវី ម៉ាស៊ីនណើរី ខបភើរេសិន សម្រាប់គម្រោងអភិវឌ្ឍន៍វារីអគ្គីសនី ស្ទឹងតាតែលើ អានុភាព ១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង។

ក្នុង**របៀបវារៈទី១ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ឧេឌ ឧន** អនុប្រធានទី២ ព្រឹទ្ធសភា បានឡើងអានរបាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៦ និងលើកទី៧ នីតិកាលទី៤។

ចំពោះ**របៀបវារៈទី២,ទី៣,ទី៤** និង**ទី៥** តំណាងរាជរដ្ឋាភិបាលដែលបានអញ្ជើញមកចូលរួមការពារសេចក្តីព្រាងច្បាប់ទាំង៤ខាងលើរួមមាន ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល ចំនួន ៤រូប ។ បន្ទាប់ពីបានស្តាប់របាយការណ៍របស់ ឯកឧត្តម **ជា ដេដ្ឋ** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ស្តីពីការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ទាំង៤ខាងលើ ស្តាប់មតិពិភាក្សាផ្តល់យោបល់របស់សមាជិក សមាជិកា អង្គប្រជុំ និងស្តាប់ការបកស្រាយបំភ្លឺរបស់តំណាងរាជរដ្ឋាភិបាលរួចមក អង្គប្រជុំព្រឹទ្ធសភា នីតិកាលទី៤ ក៏បានអនុម័តលើខ្លឹមសារទាំងមូល នៃសេចក្តីព្រាងច្បាប់ទាំង៤ខាងលើ ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ចំនួន៤០សំឡេង នៃសមាជិក សមាជិកាព្រឹទ្ធសភា ទាំងមូល៕

សកម្មភាពសមាជិកព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១២ខែកក្កដាឆ្នាំ២០២១ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ឌួន ញ៉ិល** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី១រដ្ឋសភា និងជាប្រធានក្រុមការងារគណបក្សថ្នាក់កណ្តាលចុះមូលដ្ឋានខេត្តកំពង់ធំ បានអញ្ជើញជួបប្រជុំត្រួតពិនិត្យ និងពិភាក្សាការងារមួយចំនួនជាមួយគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាខេត្តកំពង់ធំ នៅភូមិត្រពាំងស្វាយ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានីភ្នំពេញបានអញ្ជើញប្រគល់សម្ភារៈប្រើប្រាស់ និងគ្រឿងឧបភោគ បរិភោគ ដែលជាអំណោយរបស់ ឯកឧត្តម **ហ៊ុន ម៉ានី** និងក្រុមហ៊ុន Lixin Group ជូនដល់រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ សង្កាត់ពោធិ៍សែនជ័យ និងសមាគមនារីដើម្បីសន្តិភាព និងអភិវឌ្ឍខណ្ឌពោធិ៍សែនជ័យ។

ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ បានអញ្ជើញផ្តល់បទសម្ភាសន៍ផ្ទាល់ជាមួយស្ថានីយទូរទស្សន៍ CNC ពាក់ព័ន្ធនឹងប្រធានបទស្តីពីតួនាទី និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ តាមប្រពន្ធ័អនឡាញ។

ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អគ្គមេបញ្ជាការរងនៃកងយោធពលខេមរៈភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក បានដឹកនាំក្រុមការងារចុះពិនិត្យមើលទីតាំងមួយចំនួនក្នុងខេត្តឧត្តរមានជ័យ ដើម្បីរៀបចំជាមណ្ឌលព្យាបាលជំងឺកូវីដ-១៩កម្រិតស្រាលនិងមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ កម្រិតធ្ងន់ សម្រាប់បងប្អូនពលករដែលវិលត្រឡប់មកពីប្រទេសថៃ។

សកម្មភាពសមាជិកវដ្ដសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ខៀវ កាញ្ញារីទ្ធ** សមាជិកគណៈកម្មាធិការ-កណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាប្រធានក្រុមការងារ រាជរដ្ឋាភិបាលកម្ពុជា ចុះមូលដ្ឋានស្រុកកោះសូទិន ខេត្តកំពង់ចាម បានអញ្ជើញបើក យុទ្ធនាការចាក់វ៉ាក់សាំងការពារកូវីដ-១៩ នៅក្នុងបរិវេណសាលា បឋមសិក្សាជីហែ ស្រុកកោះសូទិន ។ យុទ្ធនាការចាក់វ៉ាក់សាំងក្នុងស្រុកកោះសូទិន នេះ មានគោលដៅចំនួន៧ កន្លែង មានប្រជាពលរដ្ឋត្រូវចាក់វ៉ាក់សាំង ចំនួន ៤៥ ៩៧៦ នាក់ និងមានក្រុម គ្រូពេទ្យ ចំនួន ១១ ក្រុម សរុប ១១៩ នាក់។

ឯកឧត្តម **ព្រុំ សុខា** សមាជិកគណៈកម្មាធិការកណ្តាលលគណបក្ស ប្រជាជនកម្ពុជា រដ្ឋម្រន្ត្រីក្រសួងមុខងារ សាធារណៈ និងជាប្រធានក្រុមការងារ គណបក្សចុះមូលដ្ឋានខេត្តត្រចេះ បានថ្លែងក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ អគារស្នាក់ការគណបក្សប្រជាជនកម្ពុជានៅឃុំពង្រ ស្រុកឆ្លូង ខេត្តក្រចេះ កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១ ថា ៖ ស្នាក់ការគណបក្សមិនត្រឹមតែ ជាការិយាល័យកិច្ចការបក្សប៉ុណ្ណោះទេ តែត្រូវជាកន្លែងផ្សារភ្ជាប់សុខទុក្ខជាមួយនឹងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ក្នុងពេលដែលនៅទូទាំងប្រទេសយើង កំពុងបន្តប្រយុទ្ធទ្រោលសភាពការណ៍កូវីដ-១៩ មន្ត្រីនៅមូលដ្ឋានត្រូវ៉ាប់រងផ្តល់សេវាចាំបាច់ដោយផ្ទាល់ជូនប្រជាពលរដ្ឋ ដែលពុំអាចធ្វើបានតាម Online ឬ ចំងាយ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយត្រូវកសាងទម្លាប់រស់នៅ និងបំរើការងារតាមគន្លងប្រក្រតីភាពថ្មីនៃបរិបទកូវីដ-១៩។

ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ស៊ុន ចាន់ថុល** សមាជិកគណៈកម្មាធិការ កណ្តាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អញ្ជើញចុះពិនិត្យគម្រោងពង្រីកផ្លូវជាតិលេខ៧ ជាផ្លូវ ៤គន្លង ដែលមានប្រវែងជាង ៤០គីឡូម៉ែត្រ ចាប់ពីចំណុចទីប្រជុំជនស្គន់ ស្រុកជើងព្រៃ មកដល់ចំណុចគល់ស្ពាន គីហ្សូណា ទីរួមខេត្តកំពង់ចាម។

ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ម៉ម ប៊ុនឆាង** សមាជិកគណៈ-កម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អនុប្រធានក្រុមការងារថ្នាក់កណ្តាល ចុះជួយខេត្ត និងទទួលជួយស្រុកកណ្តាលស្ទឹងខេត្តកណ្តាល ប្រធានគណៈកម្មការ ទី១០ ព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជូនដល់រដ្ឋបាលស្រុក កណ្តាលស្ទឹង សម្រាប់ចែកជូនបន្តដល់បងប្អូនប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រ ខ្វះខាត និងប្រជាពលរដ្ឋដែលកំពុងធ្វើចត្តាឡីស័ក ស្ថិតនៅមូលដ្ឋានស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ អំណោយដែលប្រគល់ជូនរដ្ឋបាលស្រុកកណ្តាលស្ទឹង នោះរួមមាន៖ ថវិកា ១២លានរៀល មី ២០០កេស ទឹកសុទ្ធ ១០០កេស ម៉ាស់ ០៥កេសធំ និងឃីត ចំនួន១០០ឃីត ។

ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **សួស យ៉ាវ៉ា** សមាជិក-គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អ្នកតំណាងរាស្ត្រមណ្ឌល ព្រះវិហារ បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះបង្រៀនយុវជនគណបក្ស ប្រជាជនកម្ពុជាខេត្តព្រះវិហារ ពីរបៀបស្លៀកពាក់ខោអាវ PE ដើម្បីការពារ សុវត្ថិភាពពីមេរោគកូវីដ-១៩ របៀបបាញ់ថ្នាំសម្លាប់មេរោគ និងការធ្វើតេស្តរក មេរោគកូវីដ១៩ជាដើម។ ឯកឧត្តមបានកោតសរសើរដល់ក្រុមការងារយុវជន គណបក្សប្រជាជនកម្ពុជាខេត្តព្រះវិហារ ដែលបានខិតខំប្រឹងប្រែងយកចិត្ត ទុកដាក់បម្រើការងារសង្គម និងការងារគណបក្សបានយ៉ាងល្អ ហើយបានលើក ទឹកចិត្តឱ្យក្រុមយុវជនទាំងនេះ ខិតខំបន្តការជួយការងារសង្គមតទៅទៀត។

សកម្មភាពសមាជិកព្រឹទ្ធសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **លី ឆេង** តំណាងរាស្ត្រមណ្ឌលរាជធានីភ្នំពេញ និងជាសមាជិកគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា បានអញ្ជើញចុះជួបសំណេះសំណាលជាមួយ ក្រុមប្រឹក្សាសង្កាត់ ប្រធានភូមិ អនុប្រធានភូមិ និងជំនួយការភូមិ ទាំង៨ នៃសង្កាត់ស្ពានថ្ម ខណ្ឌដង្កោ រាជធានី ភ្នំពេញ ។ ឯកឧត្តមបណ្ឌិត បានណែនាំដល់ប្រជាពលរដ្ឋអំពីតម្លៃនៃសាមគ្គីភាពទាំងក្នុងក្រុមគ្រួសារ និងក្រុមការងារភូមិ-សង្កាត់ និងត្រូវបន្តប្រកាន់ខ្ជាប់វិធានការអនាម័យតាមការណែនាំរបស់ក្រសួងសុខាភិបាលឲ្យបានខ្ជាប់ខ្ជួន ដើម្បីការពារ ទប់ស្កាត់កុំឲ្យឆ្លងជំងឺកូវីដ១៩ ជាពិសេសវិធានការ **"៣ការពារ- ៣កុំ"** ។

ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ជាម ប៉ែអេ** អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង និងជាសមាជិកគណៈកម្មាធិការទី៥ នៃរដ្ឋសភា រួមជាមួយ ឯកឧត្តមឧត្តមសេនីយ៍ឯក **តាន់ សុខវិជ្ជា** បានអញ្ជើញដង្ហែរទៀនព្រះវស្សា ទ័យទាន និងថវិកាមួយចំនួន ប្រគេនជូនព្រះសង្ឃគង់ចាំព្រះវស្សានៅវត្តសាន់គរ និងវត្តប្រាសាទអណ្តែត ក្នុងឃុំសាន់គរស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ ឯកឧត្តមបានថ្លែងថា យើងត្រូវរស់នៅមានសាមគ្គីភាពគ្នាក្រោមដំបូលសន្តិភាព ដែលរកបានដោយកម្រ និងមានតម្លៃមហាសាលរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី។ ឯកឧត្តមក៏បានផ្តល់ម៉ាស់ អាកុល និងថ្នាំពេទ្យ ដល់មណ្ឌលសុខភាព រដ្ឋបាលឃុំ និងប៉ុស្តិ៍នគរបាលសម្រាប់បម្រើការងារប្រចាំថ្ងៃ និងចែកជូនប្រជាពលរដ្ឋខ្វះខាតនៅមូលដ្ឋានផងដែរ។

ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ម៉ៅ ធនិន** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា និងជាប្រធានគណៈ-កម្មាធិការគណបក្សប្រជាជនកម្ពុជា ខេត្តពោធិ៍សាត់ និង ឯកឧត្តម **ម៉ក់ ង៉ា** អនុប្រធានគណៈកម្មាធិការគណបក្សខេត្ត និងជាប្រធានគណៈប្រចាំការគណបក្សខេត្តអមដោយសមាជិកគណៈអចិន្ត្រៃយ៍បក្សខេត្តរួមទាំងសមាជិកក្រុមប្រឹក្សាខេត្ត បានអញ្ជើញជាគណៈអធិបតីក្នុងពិធីប្រកាសសេចក្តីសម្រេច តែងតាំងមន្ត្រីគណបក្សប្រជាជនកម្ពុជាស្រុកបាកាន និងមន្ត្រីស្នាក់ការគណបក្សឃុំក្នុងស្រុកបាកាន ចំនួន២៧រូប នៅស្រុកបាកាន ខេត្តពោធិ៍សាត់។

ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **គួច ចំរើន** សមាជិកគណៈ-កម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ បានអញ្ជើញចុះត្រួតពិនិត្យដំណើរការម៉ាស៊ីនផលិតខ្យល់អុកស៊ីសែន នៅក្នុងបរិវេណនៃមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ។ ម៉ាស៊ីនផលិតខ្យល់អុកស៊ីសែន ដែលទើបបានដំឡើងថ្មីនេះ មានសមត្ថភាពផលិតក្នុងមួយម៉ោងបាន ៣៥ ម៉ែត្រគីប ស្មើនឹង០៥ បំពង់ ដើម្បីផ្គត់ផ្គង់ដល់មន្ទីរពេទ្យដែលមានតម្រូវការចាំបាច់ ក្នុងការជួយសង្គ្រោះដល់អ្នកជំងឺ។

ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ជាវ តាយ** សមាជិកគណៈ-កម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាខេត្តកំពត បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះ-សំណាលបង្ហាញបេក្ខជនពេញសិទ្ធិ និងបម្រុងក្រុមប្រឹក្សាក្រុងបូកគោ អាណត្តិ ទី១ ឆ្នាំ២០២១នៅស្នាក់ការគណបក្សប្រជាជនកម្ពុជាសង្កាត់បឹងទូក។ពិធីនេះមានវត្តមានអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តមអនុប្រធានគណៈកម្មាធិការគណបក្សខេត្ត និងជាប្រធានគណៈប្រចាំការគណៈកម្មាធិការគណបក្សខេត្តឯកឧត្តមលោកជំទាវ លោក លោកស្រីសមាជិក សមាជិកាគណៈអចិន្ត្រៃយ៍គណបក្សខេត្ត លោក លោកស្រីសមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សស្រុកទឹកឈូ បេក្ខជនពេញសិទ្ធិ បំរុង និងអង្គបោះឆ្នោត សរុប ៧២នាក់។

សកម្មភាពសមាជិកវដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ស្វាយ សំអ៊ាង** សមាជិក-គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈ អភិបាលខេត្តមណ្ឌលគិរី អមដំណើរដោយលោកឧត្តមសេនីយ៍ទោ **ឡោ សុខា** ស្នងការនគរបាលខេត្ត លោកមេបញ្ជាការរងកម្លាំងប្រដាប់អាវុធហត្ថខេត្ត ប្រធានមន្ទីរសុខាភិបាលខេត្ត រួមទាំងមន្ត្រីជំនាញ បានចុះជួបសំណេះសំណាល សួរសុខទុក្ខអ្នកធ្វើចត្តាឡីស័ក និងចាក់វ៉ាក់សាំងការពារឆ្លងជំងឺកូវីដ១៩ ប្រភេទស៊ីណូ៉ាក់ (Sino Vac) ជូនដល់កម្មករនិយោជិត និងនិយោជក នៅក្រុមហ៊ុន រ៉ឺនេសង់ មីនើរ៉ល ស្ថិតនៅតំបន់អូរខ្វាវ ក្នុងឃុំចុងផ្លាស់ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។

ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **អ៊ុន ចាន់ដា** សមាជិក គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជាអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម បានអញ្ជើញជាអធិបតីក្នុងពិធីបើកការដ្ឋានស្ថាបនា ផ្លូវក្រាលកៅស៊ូ២ជាន់ ប្រភេទ DBST និងផ្លូវបេតុង ១ខ្សែ មានប្រវែង ២៧.៣៥១ម៉ែត្រ ចាប់ពីចំណុចភូមិបឹងត្រាវ ឃុំសូរគង ឆ្លងកាត់ឃុំរាយប៉ាយ ឆ្ពោះទៅដល់ ស្ពានអន្លង់គគីរ ភូមិអន្លង់គគីរ ឃុំព្រែកកុយ ស្រុកកងមាស ខេត្តកំពង់ចាម ជាគម្រោងហិរញ្ញប្បទានធនាគារពិភពលោក និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា។

ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ម៉ុម សារឿន** សមាជិក-គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាអភិបាលនៃគណៈអភិបាលស្ទឹងត្រែង អមដំណើរដោយលោកអភិបាលស្រុក សេសាន លោកប្រធានមន្ទីរជំនាញពាក់ព័ន្ធមួយចំនួន បានចុះត្រួតពិនិត្យមើល ស្ថានភាពផ្លូវស្ពានលូ និងសិក្សាគម្រោង ផ្លូវមួយខ្សែបន្ថែម ដែលតភ្ជាប់ពី ភូមិស្វាយរៀង ភូមិរំពាត់ ដល់ភូមិតាឡាត ឃុំតាឡាត ស្រុកសេសាន ដែលមានប្រវែង ១៣ គីឡូម៉ែត្រ ដើម្បីសម្រួលដល់ការធ្វើដំណើររបស់បងប្អូនប្រជាពលរដ្ឋ ដោយបច្ចប្បន្ន ភូមិទាំង ៣ ក្នុង ខាងលើនេះ ពុំទាន់មានផ្លូវធ្វើ ដំណើរទៅមកក្នុងការទំនាក់ទំនងគ្នាបានស្រួលនៅឡើយទេ ។

ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ម៉ែន កុសល្យ** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ និងឯកឧត្តម **ស៊ី ប្រាសិទ្ធ** ប្រធានក្រុមប្រឹក្សាខេត្តបាន អញ្ជើញជាអធិបតីភាព ដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសចូលបំពេញការងារ លោកជំទាវ មិន ធារី អភិបាលរង នៃគណៈអភិបាលខេត្តឧត្តរមានជ័យ ដោយជំនួស ឯកឧត្តម **ឡាត់ ប៉ាវ៉ានីន** ឲ្យទៅបំពេញការងារនៅទីស្តីការក្រសួងមហាផ្ទៃ ។ ក្នុងពិធីនេះមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ អភិបាលរងខេត្ត លោកនាយក នាយករងរដ្ឋបាលសាលាខេត្ត លោកអភិបាលក្រុង-ស្រុក និងទីចាត់ការក្រោមចំណុះរចនាសម្ព័ន្ធសាលាខេត្ត ។

ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **អ៊ុំ រាត្រី** អភិបាលនៃគណៈ អភិបាលខេត្តបន្ទាយមានជ័យ អមដំណើរដោយ លោក **ហ៊ុល រ៉ាយ៉ា** អភិបាលក្រុងសិរីសាភ័ណអញ្ជើញពិនិត្យមើលដំណើរការយកសំណាកបងប្អូនអាជីវករ និងប្រជាពលរដ្ឋដែលប៉ះពាល់ផ្ទាល់ និងប្រយោលនៅផ្សារ ហ៊ុយ ឡេង ក្នុងសង្កាត់ អូរអំបិល ក្រុងសិរីសោភ័ណ ។ ឯកឧត្តមអភិបាល បានអំពាវនាវសូមបងប្អូនអ្នកមានការពាក់ព័ន្ធ ជាមួយអ្នកមានវិជ្ជមានកូវីដ១៩ នៅផ្សារហ៊ុយ ឡេង មកយកសំណាក់ទាំងអស់គ្នា ដើម្បីចូលរួមទប់ស្កាត់ការរីករាលនៃជំងឺនេះទៅក្នុងសហគមន៍។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងជាប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ ដែលមានការចូលរួមពីសមាជិកគណៈអចិន្ត្រៃយ៍នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជានៅតាមបណ្តាក្រសួង ស្ថាប័ន រាជធានី ខេត្ត និងក្រុមការងារវៀបចំអង្គការចាត់តាំងយុវជនគណបក្សនៅតាមបណ្តាប្រទេស និងទ្វីប សរុបចំនួន ៩៧រូប តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយផ្ទាល់(Zoom Meeting)។



ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១ ផ្នែកព័ត៌មាន និងបណ្តាញផ្សព្វផ្សាយសង្គម នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ដឹកនាំដោយ ឯកឧត្តម **ម៉ែន ពោធិ៍នា** សមាជិកគណៈកម្មាធិការកណ្តាលនិងជាប្រធានផ្នែកព័ត៌មាននិងបណ្តាញផ្សព្វផ្សាយសង្គម នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ដឹកនាំកិច្ចប្រជុំដើម្បីត្រួតពិនិត្យរបាយការណ៍ការងារប្រចាំឆមាសទី១ ឆ្នាំ២០២១ របស់ក្រុមផ្សព្វផ្សាយព័ត៌មានចំណុះផ្នែកព័ត៌មាន និងបណ្តាញផ្សព្វផ្សាយសង្គម និងលើកទិសដៅការងារបន្តក្នុងឆមាសទី២ ឆ្នាំ២០២១ ក្រោមអធិបតីភាព លោកជំទាវ **ហេង សំអូន** សមាជិកាគណៈកម្មាធិការកណ្តាល និងជាអនុប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ដែលមានការចូលរួមពីប្រធានក្រុមផ្សព្វផ្សាយព័ត៌មាន ព្រមទាំងសមាជិក សមាជិកា នៃផ្នែកព័ត៌មាន និងបណ្តាញផ្សព្វផ្សាយសង្គម នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល សរុបចំនួន ៣០រូប តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយផ្ទាល់(Zoom Meeting)។



ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ហួត ហាក់** សមាជិកគណៈកម្មាធិការកណ្តាល សមាជិកគណៈអចិន្ត្រៃយ៍ និងជាប្រធានលេខាធិការដ្ឋាន នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានដឹកនាំកិច្ចប្រជុំតាមដានវឌ្ឍនភាពការងាររបស់លេខាធិការដ្ឋាន និងត្រៀមរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារយុវជនគណបក្សប្រជាជនកម្ពុជាប្រចាំឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ ដែលមានការចូលរួមពីអនុប្រធាន និងក្រុមជំនួយការ នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល សរុបចំនួន ១៨រូប តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយផ្ទាល់(Zoom Meeting)។



ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២១ ឯកឧត្តម **ជ្រុន ថៅវ៉ាត** សមាជិកគណៈកម្មាធិការកណ្តាល សមាជិកគណៈអចិន្ត្រៃយ៍នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានជនបង្គោលយុវជនថ្នាក់កណ្តាលចុះជួយស្រុកព្រៃឈរព្រមទាំងអនុប្រធាន និងសមាជិក សមាជិកា បានប្រារព្ធពិធីសំណេះសំណាលអបអរសាទរខួបលើកទី៧០ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា ជាមួយក្រុមការងារយុវជនគណបក្សស្រុកព្រៃឈរ ដែលមានការចូលរួមពីប្រធានគណបក្សស្រុក ប្រធានយុវជនស្រុក និងក្រុមការងារយុវជនឃុំ សរុបចំនួន ៥២រូប តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសម្លេងដោយផ្ទាល់(Zoom Meeting)

ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ លោក **ហោ សេរីវុឌ្ឍន៍** សមាជិកគណៈអចិន្ត្រៃយ៍ និងជាប្រធានផ្នែកក្រៅប្រព័ន្ធ នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល តំណាងឯកឧត្តម **ហ៊ុន ម៉ាណែត** និងលោកជំទាវ បាននាំយកអំណោយ មានជាថ្នាំពេទ្យ Rapidតេស្ត និងម៉ាស់ តាមរយៈផ្នែកក្រៅប្រព័ន្ធ នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ជូនខេត្តមានដូចជាៈ ខេត្តបាត់ដំបង ប្រគល់អំណោយជាម៉ាស់ចំនួន ១០ ៥០០ម៉ាស់ ជូន ឯកឧត្តម **សឿម ឬទ្ធិអ៊ិ** អនុប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តបាត់ដំបង ជាតំណាងក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល។ ខេត្តសៀមរាប ប្រគល់អំណោយជាថ្នាំពេទ្យចំនួន ៣០០កញ្ចប់ និងម៉ាស់ចំនួន ៦ ០០០ម៉ាស់ ជូនឯកឧត្តម **ឡៅ សីហា** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្តសៀមរាប។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស



ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាល និងជាប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ដឹកនាំកិច្ចប្រជុំឆ្លងសេចក្តីព្រាងជំនួយស្មារតីសម្រាប់ការអនុវត្តផែនការសកម្មភាពរបស់យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដោយមានការចូលរួមពី អនុប្រធាន ប្រធានលេខាធិការដ្ឋាន ប្រធានបណ្តាផ្នែកចំណុះ និងសមាជិកផ្នែកផែនការយុទ្ធសាស្ត្រ នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ចំនួន ២៣រូប តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយផ្ទាល់ (Zoom Meeting) ។

ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ ឯកឧត្តម **ហេង សួរ** សមាជិកគណៈកម្មាធិការកណ្តាល សមាជិកគណៈអចិន្ត្រៃយ៍ និងជាប្រធានផ្នែករាជធានី ខេត្ត នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានប្រគល់សម្ភារបរិក្ខាពេទ្យ និងថវិកា ជូនលោកវេជ្ជបណ្ឌិត **ស៊ូ ស៊ីជាណ្ណា** នាយកប្រតិបត្តិ នៃសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ តំណាងសមាគមគ្រូពេទ្យស្ម័គ្រចិត្តសម្តេចតេជោ ដើម្បីជាការចូលរួមក្នុងបេសកម្មប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។



ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ពៅ ប៉ូលីណែល** សមាជិកគណៈអចិន្ត្រៃយ៍ នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជារដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិត **ម៉ៅ ហាមណ្ណាល់** សមាជិកគណៈកម្មាធិការកណ្តាល និងជាប្រធានគណៈកម្មាធិការគណបក្សរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានដឹកនាំពិធីប្រកាសសមាសភាពកែសម្រួលថ្មីនៃក្រុមការងារយុវជនគណបក្ស និងក្រុមអចិន្ត្រៃយ៍ ផែនចំណុះ ព្រមទាំងរៀបចំវគ្គបណ្តុះបណ្តាលនយោបាយខ្លី ដែលមានសមាជិក សមាជិកា ចូលរួមចំនួន ២៥រូប តាមរយៈប្រព័ន្ធ បញ្ជូនរូបភាព និងសម្លេងដោយផ្ទាល់ (Zoom Meeting) ។



ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ជាម ច័ន្ទសោភ័ណ** សមាជិកគណៈកម្មាធិការកណ្តាល និងជាអនុប្រធានផ្នែកក្រៅ ប្រទេស នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានដឹកនាំកិច្ចប្រជុំពិនិត្យវឌ្ឍនភាពការងារ និងប្រកាសសមាសភាពក្រុមជំនួយការបំពេញបន្ថែម ដើម្បីពិនិត្យលទ្ធផលការងារសម្រេចបាននាពេលកន្លងមក និងឆ្លងឯកសារគោលមួយចំនួន ដែលមានអ្នកចូលរួមចំនួន ៨១រូប តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសម្លេងដោយផ្ទាល់ (Zoom Meeting) ។



ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ឆួន ផាវ៉ត្ថ** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សរាជធានីភ្នំពេញ បានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆមាសទី១ និងលើកទិសដៅការងារប្រចាំឆមាសទី២ និងការផ្សព្វផ្សាយផែនការសកម្មភាពរបស់ យុវជនគណបក្សថ្នាក់កណ្តាល ឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ឆ្នាំ២០២២ សម្រាប់ក្រុមការងារយុវជនគណបក្សរាជធានីភ្នំពេញ តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសម្លេងដោយផ្ទាល់ (Zoom Meeting) ។

ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តម **ហាក់ សុខមករា** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សកម្ពុជាខេត្តត្បូងឃ្មុំ បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីប្រកាសកែសម្រួលរចនាសម្ព័ន្ធយុវជនស្រុកត្បូងឃ្មុំ យុវជនឃុំ និងសកម្មជនយុវជនភូមិ នៃខេត្តត្បូងឃ្មុំ និងផ្សព្វផ្សាយអំពីគោលការណ៍ក្នុងការកសាងបក្ស ការពង្រឹងសតិអារម្មណ៍យុវជនគណបក្ស និងបានផ្តោតជាសំខាន់ទៅលើ ផែនការរួម ឆ្ពោះទៅកាន់ ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ នាថ្ងៃទី ៥ ខែមិថុនា ឆ្នាំ២០២២ ខាងមុខ ដើម្បីធានាបាននូវប្រៀបឈ្នះរបស់គណបក្សប្រជាជនកម្ពុជា ដែលមានអ្នកចូលរួមចំនួន ៣១១រូប នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជាខេត្តត្បូងឃ្មុំ។

សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

រយៈពេល ៥ខែ ដើមឆ្នាំ

❋ទំហំពាណិជ្ជកម្មកម្ពុជា-ចិន សម្រេចបានចំនួន ៣.៩០៧.០៥៧.៥៦៤ ដុល្លារ កើនឡើងជាង២៥% បើធៀបនឹងរយៈពេលដូចគ្នា នៅឆ្នាំ២០២០ ដែលមានចំនួន៣.១២៣.៣៣៦.១៣៥ដុល្លារ។ក្នុងនោះការនាំចេញទំនិញរបស់កម្ពុជាទៅកាន់ប្រទេសចិនមានចំនួនសរុប ៥៥៨.៣៥៨.៥១៦ដុល្លារ កើនឡើងជាង២១% ។

❋ ទំហំពាណិជ្ជកម្មកម្ពុជា-ថៃ សម្រេចបានចំនួនជាង ៣.៣៦៥លាន ដុល្លារ ធ្លាក់ចុះ៥.២៧% បើប្រៀបធៀបនឹងរយៈពេលដូចគ្នា នៅឆ្នាំ២០២០ មានចំនួនជាង៣.៥៥២លានដុល្លារ។ ក្នុងនោះ កម្ពុជាបាននាំចេញទៅកាន់ប្រទេសថៃ មានទឹកប្រាក់ជាង៤៥៩លានដុល្លារ ធ្លាក់ចុះចំនួន ៣៦.៦១% ខណៈការនាំចូលពីថៃមានទឹកប្រាក់រហូតដល់ជាង២.៩០៥លានដុល្លារ។

❋ ទំហំពាណិជ្ជកម្មកម្ពុជា-កូរ៉េខាងត្បូង សម្រេចបានទឹកប្រាក់សរុប ៣៧៧,០៥ លានដុល្លារ កើនឡើង ៦,១៧% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០ មានត្រឹម ៣៥៥,១១លានដុល្លារ។

រយៈពេល ៦ខែ ដើមឆ្នាំ

❋ ជញ្ជីងទូទាត់កម្ពុជាបន្តទទួលបានអតិរេក ១៥៧លានដុល្លារអាមេរិក ដែលគាំទ្រដោយលំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុទោះបីជា ជំនឿភាពគណនីចរន្តបន្តកើនឡើងក៏ដោយ។ ទន្ទឹមនោះ ទុនបម្រុងអន្តរជាតិបន្តស្ថិតក្នុងកម្រិតខ្ពស់២០,៨ប៊ីលានដុល្លារអាមេរិកដែលអាចធានាការនាំចូលទំនិញ និងសេវាសម្រាប់គ្រាបន្ទាប់បានប្រមាណជាង១០ខែ។

❋ អតិផរណាជាមធ្យមមានកម្រិត ៣%ប្រហាក់ប្រហែសដូលនឹងឆមាសទី២ឆ្នាំ២០២០(៣,១%)ហើយអត្រាប្តូរប្រាក់រៀលស្ថិតក្នុងរង្វង់៤.០៨៥រៀលក្នុងមួយដុល្លារអាមេរិកដោយប្រាក់រៀលបានឡើងថ្លៃ ០,២% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។

❋ ទំហំពាណិជ្ជកម្ម អន្តរជាតិ ៖ ការនាំចេញផលិតផលកាត់ដេរមានចំនួន ៤.៧២១,៤ លានដុល្លារអាមេរិក កើនឡើង ប្រមាណ ៤០.១ លានដុល្លារអាមេរិក ស្មើនឹង ០.៩%, ការនាំចេញផលិតផលវិនិយោគមិនមែនកាត់ដេរ (ដូចជា កង់ គ្រឿងបំណែកអេឡិច ត្រូនិក បង្គុំខ្សែភ្លើង គ្រឿងបន្លាស់រថយន្ត អំពូលលម្អ កុងផ្លាកេ និងផលិតផលឧស្សាហកម្មផ្សេងៗទៀត) មានចំនួន ១.៨៩៩,៧ លានដុល្លារអាមេរិក កើនឡើង ប្រមាណ ៦៣២,៥ លានដុល្លារអាមេរិក ស្មើនឹង ៤៩.៩%។ ការនាំចេញកសិផលមានចំនួន ១.៥៨០,៦ លានដុល្លារអាមេរិក កើនឡើងប្រមាណ ៦១៧.៦ លានដុល្លារអាមេរិក ឬ ៦៤,១៣% ។

❋ គម្រោងវិនិយោគដែលបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រេចបាន៨៧គម្រោងមានទុនវិនិយោគសារុប២.៦៣៤.៦២៩.៣៣៨ ដុល្លារអាមេរិក។ ក្នុងនោះគម្រោងនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសមាន៦៤ គម្រោងមានទុនវិនិយោគ១.១០១.១៦៦.៧២២ដុល្លារអាមេរិកបង្កើតការងារបានចំនួន៤០.២៣២កន្លែង,គម្រោងក្នុងតំបន់សេដ្ឋកិច្ចពិសេសមាន២៣គម្រោង មានទុនវិនិយោគ១.៥៣៣.៤៦២.៦១៦ដុល្លារអាមេរិកបង្កើតការងារបានចំនួន៩.៧៩៧កន្លែង។ការវិនិយោគបែងចែកតាមវិស័យរួមមានវិស័យឧស្សាហកម្ម និងកសិ-ឧស្សាហកម្មមាន៩គម្រោងមានទុនវិនិយោគ ៨៩.៨២០.១៥០ដុល្លារ , ឧស្សាហកម្មនិងកម្មន្តសាលមាន ៧០គម្រោង មានទុនវិនិយោគ ១.០០៩.០៤៣.៣៦៣ដុល្លា, វិស័យទេសចរណ៍មាន ២គម្រោង មានទុនវិនិយោគ ១២៧.៨៤២.៤០០ដុល្លារ និងវិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗមាន៦គម្រោងមានទុនវិនិយោគ ១.៤០៧.៩២៣.៤២៥ដុល្លារ ។

❋ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ប្រមូលចំណូលបានចំនួន ៤.៦៩៥,៨ប៊ីលានរៀលស្មើនឹង ១.១៥៩,៥លានដុល្លារ សម្រេចបាន ៤៩% នៃផែនការឆ្នាំដែលកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ថយចុះប្រមាណ ៨.៩% ធៀបនឹងឆមាសទី ១ ឆ្នាំ ២០២០។

❋ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលពន្ធ-អាករ តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញមានចំនួន៦.១៣៩,៤១ប៊ីលានរៀល(ប្រមាណជា១.៥១៥,៩០ លានដុល្លារអាមេរិក) ស្មើនឹង៦៧,៥៨% នៃផែនការច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ធៀបនឹងចំណូលពន្ធ-អាកក្នុងរយៈពេលដូចគ្នាឆ្នាំ២០២០ ថយចុះចំនួន៧២៧,៩៨ប៊ីលានរៀល(ប្រមាណជា ១៧៩,៧៥ លានដុល្លារអាមេរិក) ស្មើនឹង -១០,៦០%។ ដោយឡែក ក្នុងរយៈពេល ២០ថ្ងៃនៃខែកក្កដា ឆ្នាំ២០២១ ប្រមូលចំណូលសរុបបានចំនួន ៣០១,០១ ប៊ីលានរៀល (ប្រមាណជា ៧៤,៣២លានដុល្លារ អាមេរិក) ។ ដូច្នេះ គិតត្រឹមថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទមានចំនួន៦.៤៤១,០៥ប៊ីលានរៀល (ប្រមាណជា១.៥៩០,៣៨ លានដុល្លារអាមេរិក)។

❋ ការនាំចេញកសិផលទៅក្រៅប្រទេស មានបរិមាណសរុប ៤.៤៥៤.៥០៥,៣៣ តោន ទៅកាន់ទិសដៅ ៦២ប្រទេស មានការកើនឡើងចំនួន ២.០៤១.៩៨២,៧២ តោនស្មើនឹង ៨៤,៦៤% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០ ដែលទទួលបានត្រឹមតែ ២.៤១២.៥២២,៦១តោន ។

❋ ការនាំចេញកៅស៊ូមានតម្លៃសរុប ២២២.៤៣២.២៦២,៩៣ ដុល្លារ ដែលក្នុងនោះចំណូលពីជ័រកៅស៊ូមាន ២២១.៦៧៥.៧៧០,០៩ដុល្លារនិងចំណូលពីឈើកៅស៊ូ ៧៥៦.៩៩២,៨៤ដុល្លារ។

❋ កម្ពុជាបាននាំចេញអង្ករសរុបចំនួន ២៨០.៤៥០តោន មានការ ថយចុះ ១១៧.២១០តោន ស្មើនឹង២៩,៤៧% បើធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល ៦ខែ ឆ្នាំ២០២០ ដែលមានចំនួន ៣៩៧,៦៦០។ ដោយឡែក សម្រាប់ការនាំចេញអង្ករក្នុងខែមិថុនា ឆ្នាំ២០២១ មានចំនួន ៤៧.៤១៩ តោន កើនឡើងចំនួន ៥.៨៥៦តោន (១៤,០៩%) បើធៀបនឹងខែមិថុនា ឆ្នាំ២០២០ ដែលមានចំនួន ៤១.៥៦៣តោន ។

❋ កម្ពុជាបាននាំចេញកង់ចំនួន ១.២៥៨.៩៧៦កង់ និងទទួលបានចំណូលចំនួន ២៤៧.៥១៥.១៩៣ដុល្លារ។ ទីផ្សារគោលដៅ ដែលកម្ពុជានាំចេញកង់រួមមាន៖ សហរដ្ឋអាមេរិក,អាល្លឺម៉ង់,ចក្រភពអង់គ្លេស,ជប៉ុន, ចិន, អាស៊ាន, ប៊ែលហ្សិក, ហូឡង់, អូទ្រីស, ស៊ុយអែត, ដាណឺម៉ាក, អូស្ត្រាលី,សាធារណរដ្ឋឆែក,អ៊ីតាលី,កូឡុំប៊ី,សាធារណរដ្ឋកូរ៉េ,អេស្ប៉ាញ, ស្លូវេនី និងកាណាដា -ល-។

❋ គិតចាប់ពីឆ្នាំ១៩៩៣ ដល់ត្រីមាសទី១ ឆ្នាំ២០២១ កម្ពុជាបានចុះកិច្ចព្រមព្រៀងទទួលកម្ចីពីដៃគូអភិវឌ្ឍន៍ស្មើទឹកប្រាក់ ១៨.៧៧២.៤ លានដុល្លារដែល ក្នុងនោះ សម្រាប់បម្រើដល់វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ចំនួន ១២.៣៥០.២លានដុល្លារ និងវិស័យអាទិភាពចំពោះមុខផ្សេងទៀតចំនួន ២.៤២២.២លានដុល្លារ។ ក្នុងកិច្ចព្រមព្រៀងកម្ចីចំនួន ១៨.៧៧២.៤ លានដុល្លារ ដកសាច់ប្រាក់បានចំនួន ៩.៨៥៧.៤លានដុល្លារ ដោយទូទាត់សេវាបំណុលបានចំនួន ២.២២៤.៤លានដុល្លារ និងសន្និធិបំណុលសាធារណៈមានចំនួន ៨.៩៨១.៣លានដុល្លារ។ នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១នេះ កម្ពុជាពុំមានការចុះកិច្ចព្រមព្រៀងផ្តល់ឥណទានថ្មីពីរដ្ឋនោះទេ ។ នៅឆ្នាំ២០២១ នេះ កម្ពុជាគ្រោងនឹងចុះហត្ថលេខា ទទួលឥណទានសម្បទានពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិពហុភាគី និងរដ្ឋាភិបាលបរទេសទ្វេភាគីចំនួន៣១គម្រោង ដែលមានទឹកប្រាក់ជាង ២.៧៤៥លានដុល្លារ ៕

វិស័យព័ត៌មាន ដើរតួនាទីយ៉ាងសំខាន់ក្នុងការបម្រើផលប្រយោជន៍ជូនសាធារណជន

*ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានលើកឡើងថា អ្នកសារព័ត៌មានកុំឱ្យប្រើប្រាស់សិទ្ធិ និងតួនាទីរបស់ខ្លួនហួសព្រំដែន*

នៅក្នុងកាលៈទេសៈដែលសកលលោក បាននិងកំពុងទទួលរងនូវមហន្តរាយ និងសោកនាដកម្មការឆ្លងរាតត្បាតនៃជំងឺកូវីដ១៩ វិស័យព័ត៌មាន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបម្រើផលប្រយោជន៍ជូនសាធារណជន និងការផ្សារភ្ជាប់ទំនាក់ទំនងរវាងរដ្ឋាភិបាលជាមួយប្រជាពលរដ្ឋ ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការនាំយកព័ត៌មានពីរដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋ ព្រមទាំងនាំយកព័ត៌មាន និងសេចក្តីត្រូវការពីប្រជាពលរដ្ឋមកកាន់រដ្ឋាភិបាលវិញ ដើម្បីដោះស្រាយបញ្ហាបានទាន់សភាពការណ៍។ ស្ថិតក្នុងស្ថានភាពដ៏លំបាក និងបញ្ហាប្រឈមបែបនេះ វិស័យព័ត៌មានកម្ពុជា បានខិតខំស្វែងរកព័ត៌មានផ្សព្វផ្សាយជូនសាធារណជនបានរហ័សទាន់សភាពការណ៍និងបានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងការឆ្លងរាលដាលជាសកលនៃជំងឺកូវីដ១៩ និងប្រឆាំងព័ត៌មានក្លែងក្លាយនៅគ្រប់ដំណាក់កាលយ៉ាងមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។

កន្លងទៅនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចតេជោ ហ៊ុន សែន** បានវាយតម្លៃខ្ពស់ចំពោះស្ថាប័នសារព័ត៌មាន និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលបានខិតខំចូលរួមបំពេញការងារជូនសង្គម និងប្រទេសជាតិ ទោះបីសភាពការណ៍នៅលើសកលលោក ក៏ដូចជានៅក្នុងព្រះរាជាណាចក្រកម្ពុជា កំពុងប្រឈមការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ក៏ដោយ។ បងប្អូនអ្នកសារព័ត៌មានបានខិតខំពុះពារជំនះរាល់ឧបសគ្គប្រឈមនឹងគ្រោះថ្នាក់បំពេញការងាររបស់ខ្លួនយ៉ាងសកម្ម ក្នុងការផ្សព្វផ្សាយព័ត៌មានជូនសាធារណជនបានយល់ដឹងសភាពការណ៍ពិតដែលបានកើតឡើង នៅក្នុងប្រទេស និងការវិវត្តនៃសភាពការណ៍នៅសកលលោកយ៉ាងទូលំទូលាយ និងរហ័សទាន់ពេលវេលា ជាពិសេសវិធានការបង្ការជំងឺកូវីដ១៩ របស់ក្រសួងសុខាភិបាល និងវិធានការរបស់រាជរដ្ឋាភិបាល ការបិទខ្ទប់ភូមិសាស្ត្រមួយចំនួននៅក្នុងប្រទេស និងវិធានការនានាដើម្បីកាត់ផ្តាច់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ នៅកម្ពុជា។ ជាមួយគ្នានេះក៏ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញបច្ចេកទេស ព្រមទាំងសីលធម៌ដល់បងប្អូនអ្នកសារព័ត៌មានឲ្យមានការអភិវឌ្ឍខ្លួន ដើរទាន់ការរីកចម្រើនបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយឌីជីថល ដើម្បីសម្រួលដល់ការបំពេញភារកិច្ចមានប្រសិទ្ធភាព ព្រមទាំងចូលរួមអនុវត្តវិធានការបង្ការជំងឺឆ្លងកូវីដ១៩របស់ក្រសួងសុខាភិបាល **"៣កុំ ៣ការពារ"** ឲ្យបានហ្មត់ចត់ខ្ជាប់ខ្ជួន និងផ្លាស់ប្តូររបៀបរស់នៅមានវិន័យតាមបែបគន្លងថ្មី ដើម្បីធានាសុវត្ថិភាពក្នុងការបំពេញភារកិច្ច និងដកស្រង់បទពិសោធន៍ បង្កើតនូវកាលានុវត្តភាពដើម្បីត្រៀមខ្លួនទៅថ្ងៃអនាគតដែលអាចប្រឈមទៅនឹងជំងឺឆ្លងរាតត្បាតសកលថ្មី ដែលមិនអាចប៉ាន់ស្មានបាន។

ដើម្បីចូលរួមចំណែកគាំទ្រ និងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្រសួងព័ត៌មាន បានរៀបចំសូចនាករគន្លឹះសម្រាប់តាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សម្រាប់រយៈពេល៥ឆ្នាំ (២០១៩-២០២៣) ដែលមានអាទិភាពសំខាន់ៗចំនួនរួមមាន៖ ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានជំរុញប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិ ពង្រឹកសក្តានុពលប្រសិទ្ធភាព និងវិសាលភាពនៃការផ្សាយគ្របដណ្តប់ឲ្យបានទូលំទូលាយទាំងក្នុងប្រទេស ក្នុងតំបន់ និងទ្វិបនានា ដើម្បីផ្តល់ព័ត៌មាន ការអប់រំ និងការកម្សាន្តប្រកបដោយគុណភាព និងសមធម៌ជូនប្រជាពលរដ្ឋខ្មែរនៅគ្រប់ច្រកល្ហកនៃមាតុប្រទេស និងឆ្ពោះទៅកាន់ពិភពលោកខាងក្រៅរួមចំណែកលើកតម្កើងអត្តសញ្ញាណរបស់កម្ពុជានៅលើឆាកអន្តរជាតិ។ ជំរុញការប្រតិកម្មតបទាន់ពេលវេលាចំពោះរាល់ការផ្សាយ និងព័ត៌មានទាំងឡាយណាដែលប្រាសចាកការពិត អាចបណ្តាលឲ្យប៉ះពាល់ដល់កិត្តិយស និងអន្តរាយដល់សន្តិសុខជាតិ និងបន្តរៀបចំផែនការទំនើបនីយកម្មមូលដ្ឋានសម្ភារៈបច្ចេកទេសជំរុញសាងសង់ស្ថានីយវិទ្យុនិងទូរទស្សន៍សម្រាប់អង្គភាពផ្សព្វផ្សាយថ្នាក់ជាតិ និងតាមបណ្តាខេត្ត ដោយផ្តល់អាទិភាពចំពោះបណ្តាខេត្តនៅប៉ែកពាយ័ព្យនិងព្យសាន្តនៃមាតុប្រទេស។ បច្ចុប្បន្នប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋមាន ស្ថានីយទូរទស្សន៍រដ្ឋ (ទទក) ស្ថានីយកណ្តាលចំនួន១ ស្ថានីយទូរទស្សន៍រដ្ឋ(ទទក) ស្ថានីយខេត្តចំនួន៩ ស្ថានីយវិទ្យុរដ្ឋ (វិទ្យុជាតិកម្ពុជា) ស្ថានីយកណ្តាលចំនួន៣ ស្ថានីយវិទ្យុរដ្ឋ (វិទ្យុជាតិកម្ពុជា) ស្ថានីយខេត្តចំនួន២៣ និងទីភ្នាក់ងារសារព័ត៌មានរដ្ឋចំនួន១។ ជាមួយគ្នានេះ ប្រព័ន្ធផ្សព្វផ្សាយឯកជន បានចូលរួមយកចិត្តទុកដាក់ ផ្សព្វផ្សាយព័ត៌មានជាតិ អន្តរជាតិ ព័ត៌មានពិតទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ ដើម្បីឲ្យប្រជាពលរដ្ឋ គ្រប់ទិសទីបានដឹង បានយល់អំពីនយោបាយ សភាពការណ៍ ក្នុងសង្គម ចំណេះដឹង

ផ្សេងៗ។ បច្ចុប្បន្នប្រព័ន្ធផ្សព្វផ្សាយឯកជនរួមមាន ស្ថានីយទូរទស្សន៍ឯកជនចំនួន១៩ ស្ថានីយទូរទស្សន៍ ខ្សែកាប (រាជធានីភ្នំពេញ) ចំនួន២, ស្ថានីយទូរទស្សន៍ខ្សែកាប (តាមបណ្តាខេត្ត) ចំនួន២១០, ស្ថានីយវិទ្យុឯកជន (រាជធានីភ្នំពេញ) ចំនួន៨៣, ស្ថានីយវិទ្យុឯកជន (តាមបណ្តាខេត្ត) ចំនួន១៣៧, ទូរទស្សន៍Digital ចំនួន៨, ទូរទស្សន៍ប្រព័ន្ធOTT ចំនួន៧, ទូរទស្សន៍ប្រព័ន្ធ Satellite ចំនួន២, សារព័ត៌មានបោះពុម្ពៈ កាសែត ព្រឹត្តបត្រ ទស្សនាវដ្តី សៀវភៅ (ភាសាខ្មែរ និងបរទេស) ចំនួន៥៨៤, គេហទំព័រ និងTVOnline ចំនួន៣៤៣, រោងពុម្ពនិងគ្រឹះស្ថានបោះពុម្ពចំនួន១១៧, សមាគមសារព័ត៌មាន ចំនួន៤០, និងទីភ្នាក់ងារសារព័ត៌មានបរទេសប្រចាំនៅកម្ពុជា ចំនួន២១ និងពង្រីកបច្ចេកទេសផ្សព្វផ្សាយរបស់រដ្ឋឲ្យបានកាន់តែទូលំទូលាយនិងកាន់តែទំនើបទាន់សម័យព្រមទាំងបង្កើនកិច្ចសហប្រតិបត្តិការជាមួយប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋនិងក្រៅប្រទេស។ ទន្ទឹមនេះ ក្រសួងព័ត៌មាន បានតាក់តែងសេចក្តីព្រាងច្បាប់ ស្តីពីសិទ្ធទទួលបានព័ត៌មាន ដើម្បីផ្តោតទៅលើផលប្រយោជន៍ និងបើកទូលាយព័ត៌មាន ដល់ប្រជាពលរដ្ឋទូទាំងប្រទេស ជ្រួតជ្រាបច្បាស់អំពីគោលនយោបាយ ការអនុវត្តផែនការសកម្មភាព ការចាត់ចែងប្រើប្រាស់ថវិកាជាតិ និងព័ត៌មានផ្សេងៗជាច្រើនទៀត ដែលរាជរដ្ឋាភិបាល បាននិងកំពុងអនុវត្ត។ ក្រសួងព័ត៌មាននឹងតាមដានជំរុញសេចក្តីព្រាងច្បាប់ខាងលើឲ្យទទួលបានការអនុម័ត និងអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត។ ក្រសួងក៏បានជំរុញការអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន និងបន្តខិតខំសិក្សាស្រាវជ្រាវ ដើម្បីកសាងលិខិតបទដ្ឋានគតិយុត្តថ្មីៗសម្រាប់គ្រប់គ្រងវិស័យព័ត៌មាននិងសោតទស្សន៍ ឲ្យស្ថិតក្នុងក្របខ័ណ្ឌនីតិរដ្ឋ ដោយធានាបានទាំងសិទ្ធិសេរីភាពនៃការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងលទ្ធិប្រជាធិបតេយ្យ និងជំរុញឲ្យទទួលបានការអនុវត្ត និងអនុវត្តក្នុងរយៈពេល៥ឆ្នាំខាងមុខជាកំហិត។ ការផ្លាស់ប្តូរប្រព័ន្ធទូរទស្សន៍ពីAnalogue ទៅDigitalផងដែរ។ បច្ចុប្បន្នក្រសួងព័ត៌មានកំពុងសិក្សាផែនការកសាងហេដ្ឋារចនាសម្ព័ន្ធទូរទស្សន៍ឌីជីថលការបំពាក់បរិក្ខារទូរទស្សន៍ឌីជីថល ការស្វែងរកដៃគូវិនិយោគ ផែនការគ្រប់គ្រងហ្វ្រេកង់ទូរទស្សន៍ បញ្ហាប្រឈមនានា និងដំណោះស្រាយ ដើម្បីរៀបចំប្រព័ន្ធទូរទស្សន៍ឌីជីថលដំណើរការផ្សាយបានយ៉ាងយូរត្រឹមឆ្នាំ២០២៣។

ជាមួយនឹងការីកចម្រើននៃបច្ចេកវិទ្យាឌីជីថលនាយុគសម័យបដិវត្តឧស្សាហកម្មជំនាន់ទី៤ បានធ្វើឲ្យទីផ្សារនៃសារព័ត៌មានប្រពៃណីដូចជាកាសែត ទស្សនាវដ្តី ព្រឹត្តិបត្រព័ត៌មាន ការធ្លាក់ចុះនាប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែជំនួសមកវិញនូវសារព័ត៌មានទំនើប ផ្សាយតាមប្រព័ន្ធអនឡាញ ។ ការីកចម្រើននៃ បច្ចេកវិទ្យាឌីជីថល បានបង្កើតឲ្យមានការផ្សាយព័ត៌មានមិនពិត តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអនឡាញ ដែលខ្វះវិជ្ជាជីវៈ និងការទទួលខុសត្រូវនិងការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម បំភ្លៃការពិត បង្កឲ្យមានភាពភ័យខ្លាច ចលាចលនៅក្នុងសង្គម។

ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មានបានគូសបញ្ជាក់ថា ក្រសួងព័ត៌មានគ្រោងនឹងបើកសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលទៅដល់អ្នកសារព័ត៌មាន ដើម្បីឲ្យពួកគេបានប្រកបវិជ្ជាជីវៈសារព័ត៌មាននៅក្នុងប្រទេសឲ្យកាន់តែមានគុណភាព។ តាមគម្រោងគឺនឹងធ្វើឡើងនៅក្នុងឆ្នាំ២០២១នេះ និងជាបន្តបន្ទាប់ទៀត ប៉ុន្តែវាក៏អាស្រ័យផងដែរទៅលើស្ថានភាពកូវីដ ក្នុងប្រទេសយើងមិនទាន់ធូរស្រាយនៅឡើយ។ យើងបានត្រៀមរៀបចំផែនការរួចហើយ ការអនុវត្តន៍គឺធ្វើទៅតាមស្ថានភាពជាក់ស្តែងបន្តទៀត។ឯកឧត្តមបានណែនាំថាប្រព័ន្ធផ្សព្វផ្សាយរដ្ឋទាំងអស់ ត្រូវផ្សាយនូវរាល់ដំណឹងផ្លូវការ ដែលចេញដោយស្ថាប័នរដ្ឋ កុំយកពីប្រភពណា ដែលមិនច្បាស់លាស់ ហើយរាល់ព័ត៌មានត្រូវរហ័ស និងមានការផ្ទៀងផ្ទាត់ឲ្យបានត្រឹមត្រូវ ទើបដំណឹងដែលផ្សាយចេញទៅទទួលបានទំនុកចិត្តពីសាធារណជន និងមានប្រសិទ្ធភាព។

ឯកឧត្តម **ខៀវ កាញារីទ្ធ** នៅក្នុងកិច្ចប្រជុំកំពូលវិស័យព័ត៌មានស្តីពី **"ការកំណត់សារឡើងវិញនូវតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយក្នុងបទដ្ឋានថ្មី"** បានគូសបញ្ជាក់អំពីតួនាទីសំខាន់នៃប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ក្នុងការផ្សព្វផ្សាយព័ត៌មានប្រកបដោយប្រសិទ្ធភាពក្នុងវិបត្តិកូវីដ១៩។ទម្លាប់នៃការប្រើប្រាស់បានផ្លាស់ប្តូរដោយមានការកើនឡើងនៃការប្រើវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញ ព្រោះអង្គភាពសារព័ត៌មាន មានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិត។ យើងបានកត់សម្គាល់ឃើញថាមានការវិលត្រឡប់ទៅប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីវិញ ដែលជាគ្រឹះវិស័យដើម្បីស្វែងរកព័ត៌មានប្រចាំថ្ងៃ។ ទន្ទឹមនេះ យើងត្រូវតែផ្តោតការខិតខំប្រឹងប្រែងរបស់យើង ក្នុងការផលិតព័ត៌មាន និងមាតិកាកម្សាន្ត ហើយក្នុងពេលតែមួយត្រូវប្រើមធ្យោបាយប្រាស្រ័យទាក់ទងផ្សេងៗ ដើម្បីផ្សព្វផ្សាយជាសាធារណៈ។ ការណ៍ដែលមានប្រព័ន្ធព័ត៌មានគ្រប់គ្រាន់គឺអាចផ្តល់នូវការចែករំលែកទិន្នន័យភ្លាមៗ និងឆាប់រហ័ស ដែលវានឹងជួយសម្រួលដល់ការយកចិត្តទុកដាក់ក្នុងការអន្តរាគមន៍ជួយ ក៏ដូចជាការឆ្លើយតបបានទាន់ពេលវេលា ជាពិសេសសម្រាប់ប្រជាជននៅតំបន់ដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ។ ឯកឧត្តមរដ្ឋមន្ត្រីបានបន្តថាជំងឺកូវីដ១៩បានបង្ហាញពីកង្វះខាតនៃរចនាសម្ព័ន្ធ និងដំណើរការ ដែលមានប្រសិទ្ធភាពចាំបាច់នៅក្នុងប្រព័ន្ធសង្គមឌីជីថល។ ទន្ទឹមនេះ និន្នាការកើនឡើងដែលបានបង្ហាញដោយប្រព័ន្ធផ្សព្វផ្សាយប្រពៃណីនៅក្នុងប្រទេសជាច្រើន ដែលមានតម្លៃថោកសម្រាប់ពលរដ្ឋប្រើប្រាស់ចាំបាច់ត្រូវធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធផ្សព្វផ្សាយប្រពៃណីដើម្បីធានាបាននូវនិរន្តរភាព។

រាជរដ្ឋាភិបាលកម្ពុជា បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការលើកកម្ពស់សិទ្ធិសេរីភាពនៃការបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន ការលើកស្ទួយនូវឯករាជភាពនៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានពហុនិយម និងធានាសុវត្ថិភាពដល់អ្នកសារព័ត៌មានក្នុងការបំពេញភារកិច្ចតាមវិជ្ជាជីវៈរបស់ខ្លួនដោយគ្មានការភ័យខ្លាច។ ព្រមជាមួយគ្នានេះគឺជំរុញតួនាទីរបស់ស្ថាប័នសារព័ត៌មានឲ្យកាន់តែសកម្មថែមទៀត ដើម្បីបម្រើផលប្រយោជន៍សាធារណជន ក្នុងការចូលរួមចំណែកលើកស្ទួយសុខុមាលភាពសង្គម និងសុខដុមនីយកម្មសកលដែលជាបំណងប្រាថ្នារបស់មនុស្សជាតិទូទាំងសកលលោក៕

វឌ្ឍនភាពនៃការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវជាតិ និងផ្លូវក្នុងក្រុង

*ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អញ្ជើញសិក្ខាការស្ថាបនាផ្លូវនាពេលកន្លងមក*

ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវ ៣៨ ខ្សែនៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប

វិស័យដឹកជញ្ជូនជាចង្វាក់បេះដូងនៃកំណើនសេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍសង្គម។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងប្រព័ន្ធដឹកជញ្ជូនមានគុណភាពខ្ពស់ ធន់នឹងបម្រែបម្រួលអាកាសធាតុ គឺជាមូលដ្ឋានគ្រឹះនៃការកសាងប្រទេសជាតិឲ្យភ្លាយទៅជាប្រទេសអភិវឌ្ឍ ។ ការប្រែប្រួលយ៉ាងឆាប់រហ័សនៃនិម្មាបនកម្មពិភពលោក តំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានគូសបញ្ជាក់ច្បាស់ពីកាលានុវត្តភាពសម្រាប់អភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន ដែលជាចំណែកដ៏សំខាន់ដល់ការផ្លាស់ប្តូរក្របខណ្ឌសង្គម និងសេដ្ឋកិច្ចកម្ពុជា តាមរយៈការបង្កើតហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនប្រទាក់ក្រឡាប្រកបដោយគុណភាព ប្រសិទ្ធភាព សុវត្ថិភាព និងតម្លៃសមរម្យដែលអាចបង្កើតចេញជាបរិយាកាសអំណោយផលដល់ការវិនិយោគ ការបង្កើតការងារ ការបង្កើនចំណូល និងការលើកកម្ពស់ផលិតភាព និងការទទួលបាននូវបច្ចេកទេស បច្ចេកវិទ្យា និងវិទ្យាសាស្ត្រថ្មីៗ ទន់ភ្លន់ និងបត់បែនក្នុងយុគសម័យនៃការរីករាលដាលជំងឺឆ្លងកូវីដ-១៩ ។ ក្នុងបរិការណ៍នេះទោះបីកម្ពុជានិងពិភពលោកទាំងមូលកំពុងប្រឈមនឹងវិបត្តិជំងឺកូវីដ-១៩ តែប្រមុខរាជរដ្ឋាភិបាលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា នៅតែបន្តសម្រុក ជំរុញការកសាងបណ្តាញផ្លូវជាតិ និងផ្លូវសេដ្ឋកិច្ចសំខាន់ៗយ៉ាងសកម្ម។

ជាក់ស្តែង បន្ទាប់ពីការស្ថាបនាពង្រីកផ្លូវចំនួន ៣៤ខ្សែនៅក្រុងព្រះសីហនុ សម្រេចបានលទ្ធផល ស្ទើរ១០០% ពេលនេះរាជរដ្ឋាភិបាលបានឈានមួយជំហានទៀត ដោយបានចំណាយប្រាក់រាប់រយលានដុល្លារដើម្បីកសាងពង្រីកផ្លូវចំនួន ៣៨ខ្សែទៀតនៅក្រុងសៀមរាប ដើម្បីលើកកម្ពស់មុខមាត់របស់ខេត្ត លើកកម្ពស់សោភ័ណភាព ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ផងដែរ។ ផ្លូវទាំង៣៨ខ្សែនេះសម្រេចបានលទ្ធផលប្រមាណ៤០% ហើយដែលសមិទ្ធផលនេះ បាននិងកំពុងបង្ហាញពីមហិច្ឆតារបស់រាជរដ្ឋាភិបាលក្នុងការជំរុញ និងលើកកម្ពស់សេដ្ឋកិច្ចជាតិ ពិសេសបង្កើន កិត្យានុភាពជាតិ នៅលើទឹកដីអង្គរដ៏ល្បីល្បាញរបស់កម្ពុជា។

ដោយឡែកការសាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-ព្រះសីហនុ សម្រេចបាន លទ្ធផល ៦០% ខណៈគម្រោងសាងសង់ផ្លូវនេះនឹងបញ្ចប់នៅឆ្នាំ២០២៣ខាងមុខ ឬលឿនជាងនេះ។ ក្រោយពេលសាងសង់រួចរាល់គម្រោងផ្លូវនេះនឹងជាផ្នែកមួយដ៏សំខាន់ក្នុងការជួយលើកស្ទួយដល់សេដ្ឋកិច្ចប្រទេសកម្ពុជា។ នេះជាគម្រោងអភិវឌ្ឍន៍បែបបៃតងជាលើកដំបូងនៅកម្ពុជា ហើយក៏ជាផ្លូវប្រវត្តិសាស្ត្ររបស់កម្ពុជាផងដែរ ដោយសារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនេះ ស្ថិតនៅក្នុងគម្រោងខ្សែក្រវាត់១ ផ្លូវ១របស់ប្រទេសចិន។ ឯកឧត្តម **ង៉ាស៊ីម សូរិយោ** អ្នកនាំពាក្យក្រសួងសាធារណៈការ និងដឹកជញ្ជូនបានឲ្យដឹងថា ការកសាងផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុធ្វើឡើងតាមស្តង់ដាអន្តរជាតិ ដែលវាជាផ្លូវជាប់ធន់ និងប្រើប្រាស់បានយូរ។ ផ្លូវល្បឿនលឿន ភ្នំពេញ-ព្រះសីហនុ គ្រោងចំណាយទឹកប្រាក់សាងសង់១.៩០០ លានដុល្លារអាមេរិក។ អ្នកគ្រប់គ្រងគម្រោងផ្លូវល្បឿនលឿនបានបញ្ជាក់ថា ផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ បាននិងកំពុងស្ថាបនាដោយផ្នែកលើបច្ចេកវិទ្យា ដែលមិនប៉ះពាល់ដល់បរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព។ ផ្លូវល្បឿនលឿននេះមិនត្រឹមតែជួយជំរុញសេដ្ឋកិច្ច កម្ពុជាប៉ុណ្ណោះទេ ថែមទាំងដឹកនាំ **"និន្នាការបៃតង"** នៅក្នុងឧស្សាហកម្មហេដ្ឋារចនាសម្ព័ន្ធ ដើម្បីការពារបរិស្ថានរបស់ប្រទេសកម្ពុជាផងដែរ។ ផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុត្រូវបានបង្កើតឡើងដោយផ្នែកលើមូលដ្ឋានប្រតិបត្តិការរវាងរដ្ឋាភិបាល និងឯកជន។ បន្ទាប់ពីបញ្ចប់ផ្លូវនេះនឹងក្លាយជាផ្លូវល្បឿនលឿនដំបូងគេបង្អស់របស់ប្រទេសកម្ពុជា ដោយភ្ជាប់រាជធានីភ្នំពេញទៅកំពង់ផែសមុទ្រធំជាងគេនៃខេត្តព្រះសីហនុ។ ការធ្វើដំណើរនឹងចំណាយពេលត្រឹមតែ២ម៉ោងប៉ុណ្ណោះ បើប្រៀបធៀបនឹងបច្ចុប្បន្នត្រូវចំណាយពេលរយៈពេល៥ម៉ោង ។ ផ្លូវនេះមានចំណុចពិសេសមួយចំនួនខុសពីផ្លូវធម្មតាដូចជា មានចំណតឈប់សម្រាកចំនួន៣ កន្លែង, មានស្ពានតូច៥កន្លែង និងស្ពានធំចំនួន៨០កន្លែង

វឌ្ឍនភាពនៃគម្រោងសាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-ព្រះសីហនុ ប្រវែង១៩០គីឡូម៉ែត្រ

មានប្រវែង សរុប ៦០១៥ម៉ែត្រ, មានស្ពានអាកាសដែលមានសណ្ឋានដូចស្ពានអាកាសស្នឹង មានជ័យ៦កន្លែង, ផ្លូវនេះនឹងត្រូវធ្វើរបងបិទជិត មិនឲ្យសត្វពាហនៈ ម៉ូតូ និងរ៉ឺម៉ក ម៉ូតូឆ្លងកាត់បាននោះទេ, មានមណ្ឌលប្រតិបត្តិការថែរទាំយានយន្តចំនួន ១កន្លែង ពិសេសកន្លែងបង់លុយសម្រាប់រថយន្តឆ្លងកាត់។ ផ្លូវមានចម្ងាយខ្លីធៀបជាមួយផ្លូវជាតិលេខ៤ ដែលមានចម្ងាយ ២២៤គីឡូម៉ែត្រ តែផ្លូវនេះមានចម្ងាយជាង១៩០ គីឡូម៉ែត្រប៉ុណ្ណោះ។ ផ្លូវនេះតម្រូវឲ្យអ្នកបើកបរយានយន្តបើកបរក្នុងល្បឿន ៩០ទៅ១៦០គីឡូម៉ែត្រក្នុងមួយម៉ោង។

ព្រមជាមួយគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ នេះ រាជរដ្ឋាភិបាលបាននិងកំពុងកសាងបណ្តាញផ្លូវជាតិ និងផ្លូវសេដ្ឋកិច្ចសំខាន់ៗមួយចំនួនទៀតយ៉ាងសកម្ម ជាក់ស្តែងផ្លូវជាតិលេខ២ បាននិងកំពុងសាងសង់ដោយតភ្ជាប់ពីក្រុងតាខ្មៅ ខេត្តកណ្តាល ទៅកាន់ខេត្តតាកែវ និងតភ្ជាប់ចេញពីក្រុងដូនកែវទៅកាន់ទីប្រជុំជនអង្គតាសោម នៃផ្លូវជាតិលេខ៣។ បច្ចុប្បន្នការស្ថាបនាពង្រីក (ពង្រីក នៅតំបន់ខ្លះ) បាននិងកំពុងសាងសង់ដោយសម្រេចបានប្រមាណ ៤០%។ ដោយឡែក ផ្លូវជាតិលេខ៣ ដែលភ្ជាប់ពីស្ពានអាកាសចោមចៅដល់ក្រុងកំពតចម្ងាយ ១៤៨គីឡូម៉ែត្រ បានបញ្ចប់ការស្ថាបនាស្មើរ១០០%។ ដែលធ្វើការវិនិយោគនៅទឹកដីខេត្តកំពតកើនឡើងយ៉ាងរហ័ស។ ផ្លូវជាតិលេខ៣ ត្រូវបានពង្រីកជាពីរគន្លង រថយន្តទៅមកដោយមានសួនច្បារចំកណ្តាល ចាប់ផ្តើមពីតំបន់ស្ពានអាកាស ចោមចៅរហូតដល់ចំណុចថ្នល់បំបែកបាយគូស (ចំណុចផ្លូវបំបែកកំពត- កែប) និងចាប់ពីចំណុចបាយគូសដល់ក្រុងកំពតត្រូវបានពង្រីកទំហំត្រឹម ១២ម៉ែត្រ។ ចំពោះផ្លូវជាតិលេខ៥ ដែលត្រូវបានចាត់ទុកជាផ្លូវហាយវេអាស៊ាន មានប្រវែងជិត៤០០ គីឡូម៉ែត្រ និងចំណាយថវិកាសាងសង់ជាង ៥០០លានដុល្លារអាមេរិក ជាហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលជប៉ុនក៏កំពុងត្រូវបានសាងសង់យ៉ាងសកម្ម។ ផ្លូវជាតិដ៏សំខាន់នេះឆ្លងកាត់រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង និងខេត្តបន្ទាយមានជ័យ។ ការសាងសង់ផ្លូវជាតិ នេះសម្រេច លទ្ធផលបានជាង ៤០% និងគ្រោងបញ្ចប់នៅឆ្នាំ២០២៣ ។ នៅពេលសាងសង់បញ្ចប់ផ្លូវជាតិនេះ នឹងក្លាយជាចំណុចតភ្ជាប់ និងការដឹកជញ្ជូនទំនិញពីប្រទេសថៃឆ្លងកាត់កម្ពុជាមុនតភ្ជាប់ទៅកាន់ប្រទេស វៀតណាម។ រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយដោយ រៀបចំតំបន់ជាប់ផ្លូវជាតិលេខ៥ ជាសួនឧស្សាហកម្មដែលអាចទទួលបានផលប្រយោជន៍ពីការដឹកជញ្ជូនទំនិញឆ្លងកាត់រវាងប្រទេសថៃ និងប្រទេសវៀតណាម។ ចំពោះផ្លូវជាតិលេខ១០ ជាផ្លូវជាតិប្រវត្តិសាស្ត្រថ្មីមួយ មានប្រវែងជាង ១៩០ គីឡូម៉ែត្រ ស្ថាបនាជើងតភ្ជាប់ពីតំបន់ភូមិភាគ ៣យ៉ាងទៅកាន់តំបន់សមុទ្រជាលើកដំបូង។ ផ្លូវជាតិនេះតភ្ជាប់ពីស្រុកសំឡូត ខេត្តបាត់ដំបង ឆ្លងកាត់ខេត្តពោធិសាត់ តភ្ជាប់ទៅកាន់ ខេត្តកោះកុង ដែលជាមូលដ្ឋានកំពង់ផែទឹកជ្រៅថ្មីមួយសម្រាប់ការដឹកជញ្ជូនកសិផលទៅកាន់ប្រទេសទី៣ ដោយកាត់បន្ថយការពឹងផ្អែកប្រទេសជិតខាង។ ផ្លូវជាតិលេខ១០ សម្រេចលទ្ធផលសាងសង់បានជាង៥០% គិតរហូតមកទល់ពេលនេះ ដែលគម្រោងនេះនឹងបញ្ចប់នៅចុងឆ្នាំ ២០២២ ខាងមុខ។ ចំណែកផ្លូវក្រវាត់ក្រុងទី៣ នៃរាជធានីភ្នំពេញ ការកសាង ប្រវែងជាង៥៦គីឡូម៉ែត្រនេះ បាននិងកំពុងទាក់ទាញគម្រោងវិនិយោគធំៗជាច្រើនឲ្យទៅវិនិយោគនៅទីនោះ។ តំបន់ជុំវិញផ្លូវក្រវាត់ក្រុងទី៣ ដែលធ្លាប់ជាបឹងជាត្រពាំង និងជាអូរត្រូវបានចាក់បំពេញ និងជំនួសមកវិញដោយគម្រោង អភិវឌ្ឍន៍លំនៅដ្ឋានមជ្ឈមណ្ឌលពាណិជ្ជកម្ម ព្រលានយន្តហោះអន្តរជាតិ ។ បច្ចុប្បន្នការ ស្ថាបនាផ្លូវនេះ សម្រេចបានលទ្ធផលជាង៥០% ខណៈស្ពានធំៗមួយចំនួនក៏បាននិងកំពុងជិតបញ្ចប់ការសាងសង់ផងដែរ។

ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន បាន បញ្ជាក់ឲ្យដឹងថា ទោះបីកម្ពុជា កំពុងប្រឈមនឹងវិបត្តិជំងឺកូវីដ-១៩ ប៉ុន្តែការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់កម្ពុជាមិនបានបញ្ឈប់ទេ គ្រាន់តែយឺតយ៉ាវបន្តិចប៉ុណ្ណោះ ពោលគឺគ្មានគម្រោងសាងសង់ណាមួយត្រូវបានអាក់ខាន ឬបញ្ឈប់ដោយសារវិបត្តិនៃជំងឺនេះទេ ៕



ស្ថាបនាពង្រីកផ្លូវចំនួន ៣៤ខ្សែនៅក្រុងព្រះសីហនុ សម្រេចបានលទ្ធផល ស្មើរ១០០%

លើកកម្ពស់សិទ្ធិ សេរីភាព សុខុមាលភាព និងគុណភាពជីវិតរបស់ជនមានពិការភាព

តាមរយៈគោលនយោបាយលើកកម្ពស់ជីវភាពជនមានពិការភាពដែលក្រីក្រ និងយន្តការនានារបស់រាជរដ្ឋាភិបាល ជនមានពិការភាពមានឱកាសចូលបម្រើការនៅស្ថានប័នរដ្ឋ និងវិស័យឯកជនមានការកើនឡើងរហូតដល់ជាង ១ម៉ឺននាក់នៅក្នុងឆ្នាំ២០២០ បើប្រៀបធៀបនឹងឆ្នាំ២០១៩ កន្លងមក ដែលមានជនពិការចូលបម្រើការងារនៅតាមស្ថាប័នរដ្ឋនិងវិស័យឯកជនមានចំនួនត្រឹមតែជាង៦ពាន់នាក់ប៉ុណ្ណោះ។

តាមរបាយការណ៍ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា បានបញ្ជាក់ថា ក្រៅពីកិច្ចខិតខំប្រឹងប្រែង និងជួយលើកកម្ពស់ជីវភាពជនមានពិការភាពដែលក្រីក្រតាម រយៈគោលនយោបាយ និងយន្តការនានារាជរដ្ឋាភិបាលក៏តែងតែបានអំពាវនាវដល់គ្រប់ក្រសួងស្ថាប័នរដ្ឋ និងវិស័យឯកជន ធ្វើយ៉ាងណាបង្កលក្ខណៈងាយស្រួលដល់ការដាក់ពាក្យចូលបម្រើការងារក្នុងស្ថាប័នរដ្ឋ ក្នុងក្រសួងនីមួយៗឲ្យបាន២% តាមច្បាប់ដែលបានចែង និងវិស័យឯកជនឲ្យបាន១%ក្នុងក្រុមហ៊ុននីមួយៗផងដែរ។ បើទោះបីជាបងប្អូនជនពិការបានចូលបម្រើការងារក្នុងវិស័យឯកជន និងស្ថាប័នរដ្ឋមានការកើនឡើងយ៉ាងណាក៏ដោយ ក៏បងប្អូនជនពិការនៅជួបបញ្ហាប្រឈមមួយចំនួន ជាពិសេសកត្តាចំណេះដឹង និងគ្មានជំនាញវិជ្ជាជីវៈច្បាស់លាស់ដែលបញ្ហាប្រឈមទាំងអស់នេះ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ធ្វើយ៉ាងណាជួយដល់បងប្អូនពិការភាពអាចទទួលការអប់រំបានខ្ពង់ខ្ពស់ និងជួយបង្រៀនជំនាញវិជ្ជាជីវៈ ពិតប្រាកដដែលងាយ ស្រួលក្នុងការប្រកបការងារ ។ ផ្អែកតាមរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា កម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែង ធ្វើការងារជាច្រើន ដើម្បីលើកកម្ពស់សិទ្ធិ សេរីភាព សុខុមាលភាពនិងគុណភាពជីវិតរបស់ជនមានពិការភាព។ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពដល់ការងារពិការភាព ដោយបានដាក់ចេញផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ២០១៩-២០២៣ បានកសាងគោលនយោបាយ និងលិខិតបទដ្ឋានជាបន្តបន្ទាប់សំដៅពង្រឹងពង្រីកការគោរពសិទ្ធិជាមូលដ្ឋានរបស់ជនមានពិការភាព។ អតីតយុទ្ធជនពិការ អតីតមន្ត្រីរាជការជាជនមានពិការភាព បានទទួលរបបឧបត្ថម្ភពីរដ្ឋ។ ជនមានពិការភាពគ្រប់ប្រភេទ បានទទួលសេវាស្តារលទ្ធភាព ពលកម្ម កាយសម្បទា និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយឥតគិតថ្លៃសេវាអក្សរស្ទាប និងភាសាសញ្ញាសម្រាប់ជនមានពិការ។ ដោយសារប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាម និងរបបប្រល័យពូជសាសន៍បានបន្សល់ទុកផលវិបាកជាច្រើននៅក្នុងសង្គមក្នុងនោះមានអត្រាជនមានពិការភាពខ្ពស់។ ទន្ទឹមនោះគ្រោះថ្នាក់ដោយសារគ្រាប់មីន គ្រាប់មិនទាន់ផ្ទុះ គ្រោះថ្នាក់ ការងារ

*ឯកឧត្តមរដ្ឋមន្ត្រី **វង សូត** អញ្ជើញចុះជួបសំណេះសំណាលជាមួយបងប្អូនជនពិការក្រីក្រ*

គ្រោះថ្នាក់ចរាចរណ៍ កង្វះអាហារូបត្ថម្ភ ជំងឺតម្កាត់ និងពិការ ដោយមូលហេតុផ្សេងៗ ក៏ធ្វើឱ្យចំនួនជនមានពិការភាពមានការកើនឡើងដែលភាគច្រើនជាជនក្រីក្រ និងងាយរងគ្រោះ ជាងគេនៅក្នុងសង្គម។

សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីកិច្ចការពារ លើកកម្ពស់សិទ្ធិជនពិការត្រូវបានបង្កើតឡើង ឆ្លើយតបនឹងតម្រូវការរបស់ជនមានពិការភាព និងសេវាស្តារលទ្ធភាពពលកម្មនៅក្នុងសហគមន៍ ព្រមទាំងបានជួយលើកកម្ពស់ជីវភាពរស់នៅរបស់ជនមានពិការភាព និងបង្កើនការអនុវត្តសិទ្ធិចូលរួមរបស់ជនមានពិការភាពក្នុងសកម្មភាពសង្គមផងដែរ។ ជនមានពិការភាពបានពង្រឹងភាពម្ចាស់ការរបស់ខ្លួនតាមរយៈការបង្កើតអង្គការតំណាងសហព័ន្ធ ចងក្រងក្រុមជួយខ្លួនឯងនៃជនមានពិការភាព, ការរើសអើងជនមានពិការភាពត្រូវបានកាត់បន្ថយជាច្រើន ហើយសិទ្ធិស្របច្បាប់របស់ជនមានពិការភាពត្រូវបានការពារនិងលើកកម្ពស់។

ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ក្រោមការដឹកនាំពីឯកឧត្តមរដ្ឋមន្ត្រី **វង សូត្រ** បានបញ្ជាក់ពីការយកចិត្តទុកដាក់លើការងារនេះយ៉ាងសកម្មបំផុតពង្រឹង និងពង្រីកការផ្តល់មូលនិធិជនមានពិការ តាមរយៈក្រុមប្រឹក្សាឃុំ សង្កាត់ និងរៀបចំ ឬដាក់បញ្ចូលកញ្ចប់ថវិការដ្ឋ និងកៀរគរធនធានប្រភពទុនពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដៃគូរអភិវឌ្ឍន៍សង្គមស៊ីវិលសប្បុរជន និងការចូលរួមពី សហគមន៍មូលដ្ឋានសម្រាប់ការបណ្តុះបណ្តាលជំនាញ និងបង្កើតមុខរបរតាមតម្រូវការទីផ្សារក្នុងសហគមន៍ ព្រមទាំងធ្វើការបញ្ជ្រាបឲ្យជនមានពិការភាពធ្វើការងារតាមរោងចក្រ សហគ្រាសសាធារណៈ ឬឯកជននានា និងទំនាក់ទំនងរកទីផ្សារសម្រាប់ផលិតផលរបស់ជនមានពិការភាព ។ ផ្តល់របបគោលនយោបាយចំពោះជនពិការ និងមនុស្សវ័យចាស់ក្រីក្រនៅតាមសហគមន៍ ផ្តល់ប័ណ្ណសម្គាល់ពិការភាព ប័ណ្ណសមធម៌ ដើម្បី

ជនមានពិការភាពនៅកម្ពុជាបានទទួលការយកចិត្តទុកដាក់ជួយទំនុកបម្រុងពីរាជរដ្ឋាភិបាល

យកទៅប្រើប្រាស់ជាប្រយោជន៍ក្នុងជីវភាពរស់ប្រចាំថ្ងៃរបស់ពួកគាត់ និងបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាព និងមនុស្សវ័យចាស់ឲ្យទទួលបានសេវានានាប្រកបដោយសមធម៌ និងបរិយាបន្ន ស្របតាមគោលនយោបាយជាតិគាំពារសង្គម ព្រមទាំងការផ្តល់សេវាសុខភាព សេវាយុត្តិធម៌ សេវាអប់រំ ដោយឥតគិតថ្លៃ ។ បញ្ជៀបការយល់ដឹងពីពិការភាព លុបបំបាត់ជំនឿបុណ្យ បាប និងអំពើអកុសលនាំឲ្យមានពិការភាពក្នុងចំណោមព្រះសង្ឃបព្វជិតសហគមន៍ក្រុមគ្រួសារ និងបង្កើនសាមគ្គីភាពរវាងអ្នកមិនមានពិការភាព និងពិការភាព ជំរុញការលើកទឹកចិត្តម្ចាស់កម្មវិធីឲ្យធ្វើបរិយាបន្ន និងអញ្ជើញជនមានពិការភាពក្នុងកម្មវិធីរបស់ខ្លួន។

